# ផ្នែក ខ

# លក្ខណៈសំខាន់នៃឧបករណ៍នាវិកវៃឆ្លាត

# ផ្នែក ខ

# លក្ខណៈសំខាន់នៃឧបករណ៍នាវិកវៃឆ្លាត



# មេរៀនទី៣ ៖ លក្ខណៈសំខាន់នៃឧបករណ៍នាវិកវៃឆ្លាត

## ចំណុចបំណង

អ្នកចូលរួមនឹងបានយល់ដឹងអំពីរបៀបប្រើប្រាស់ឧបករណ៍នាវិកវៃឆ្លាតនេះ ហើយនឹងយល់អំពីគោលបំណងនៃលក្ខណៈសំខាន់ៗដ៏ជាក់លាក់។

## រយៈពេល

៦០ នាទី

## សម្ភារៈ

- ឧបករណ៍នាវិកវៃឆ្លាតដែលបានថតចម្លងសម្រាប់អ្នកចូលរួមនីមួយៗ
- «ប័ណ្ណព័ត៌មានលេខ៣កៈបញ្ជីត្រួតពិនិត្យៈយុវជនដែលមិនចេះអានអក្សរបាន»

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ ពី២ ទៅ៣ រូប មកពីក្លឹប SNYC នីមួយៗ។

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្ដុះបណ្ដាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP។

## សេចក្ដីផ្ដើមស្ដីពីលក្ខណៈសំខាន់ៗនៃឧបករណ៍នាវិកឆ្លាត

ចូរប្រាប់ឲ្យអ្នកចូលរួម ឲ្យយកឧបករណ៍នាវិកវៃឆ្លាតរបស់ពួកគាត់ចេញមកហើយបើកត្រង់ «មេរៀនទី១ ៖ ការណែនាំអំពីក្លឹបរបស់យើង»។

អានផ្នែកខាងក្រោមនេះឮៗទៅកាន់អ្នកចូលរួម នៅពេលពួកគាត់មើលឧបករណ៍នាវិកវៃឆ្លាតរបស់ពួកគាត់។

## ទិដ្ឋភាពទូទៅស្តីពីឧបករណ៍នារីកវៃឆ្លាត

ពន្យល់ថា ឧបករណ៍នារីកវៃឆ្លាតនេះមានប្រាំមួយផ្នែក ៖

- ផ្នែក ក៖ បង្កើតក្លឹបយុវជននារីកវៃឆ្លាត
- ផ្នែក ខ៖ ព័ត៌មានអំពីការជួញដូរមនុស្ស
- ផ្នែក គ៖ បំនិនជីវិតដែលអាចកសាងលទ្ធភាពផ្ទាល់ខ្លួនដើម្បីប្រឆាំងតប
- ផ្នែក ឃ៖ រៀបចំផែនការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព
- ផ្នែក ង៖ ចាត់វិធានការ
- ផ្នែក ច៖ សេចក្តីសង្ខេបអំពីចំណុចសម្របសម្រួលសំខាន់ៗ

## លក្ខណៈសំខាន់ៗរបស់ឧបករណ៍នារីកវៃឆ្លាត

ពន្យល់ថា មេរៀននេះមានលក្ខណៈសំខាន់បន្តបន្ទាប់គ្នា ដែលត្រូវបានរៀបរាប់ឡើង វិញ។ លក្ខណៈសំខាន់មួយចំនួន ត្រូវបានបង្កើតឡើងដើម្បីជួយអ្នកសម្របសម្រួលក្លឹប SNYC ធ្វើផែនការសម្រាប់មេរៀន។ លក្ខណៈពិសេសផ្សេងទៀត ត្រូវបានបង្កើតឡើងដើម្បីជួយអ្នកចូលរួម ឲ្យមានការយល់ដឹងអំពីប្រធានបទមួយកាន់តែស៊ីជម្រៅ។ ខាងក្រោមនេះគឺជាសេចក្តី សង្ខេបនៃលក្ខណៈសំខាន់ទាំងនេះ ៖

### វត្ថុបំណង

ផ្នែកនេះប្រាប់អ្នកសម្របសម្រួលក្លឹប SNYC អំពីអ្វី ដែលអ្នកចូលរួមនឹងបានយល់ដឹងអំពីមេរៀន។

### សម្ភារ

ផ្នែកនេះ រៀបរាប់អំពីតម្រូវការរបស់អ្នកសម្របសម្រួលក្លឹប SNYC ដើម្បីដឹកនាំបង្រៀនមេរៀន។ សម្ភារទាំងនេះ នឹងត្រូវបានផ្តល់ឲ្យដោយអង្គការទស្សនៈពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ អ្នកសម្របសម្រួល ក្លឹប SNYC ប្រហែលជាត្រូវការត្រៀមរៀបចំបន្តិចបន្តួចផងដែរ។ ឧទាហរណ៍ ថតចម្លងប័ណ្ណព័ត៌មានសម្រាប់ចែកជូនអ្នកចូលរួមគ្រប់ៗគ្នា។ អ្នកសម្របសម្រួលក្លឹប SNYC ក៏អាចសុំឲ្យអ្នកចូលរួមក្លឹប SNYC ជួយក្នុងកិច្ចការផ្សេងៗ ឧទាហរណ៍ កិច្ចការកាត់ខ្លឹមសារផ្សេងៗចេញពីប័ណ្ណព័ត៌មាន ។ អ្នកសម្របសម្រួលក្លឹប SNYC គួរអានបញ្ជីសម្ភារមួយសប្តាហ៍មុនពេលចាប់ផ្តើមមេរៀន ដើម្បីឲ្យខ្លួនមានពេលវេលាសម្រាប់រៀបចំ។

### ការរៀបចំ

ចូរពន្យល់ថា មេរៀនមួយចំនួនមានកំណត់សម្គាល់ស្តីពីការរៀបចំ។ កំណត់សម្គាល់នេះអាចរួមបញ្ចូលការពន្យល់ទៅកាន់អ្នកចូលរួមមុនពេលចាប់ផ្តើមមេរៀនថាខ្លឹមសារនៃមេរៀនបន្ទាប់មានលក្ខណៈងាយប៉ះពាល់ដល់អារម្មណ៍។ អ្នកសម្របសម្រួលក្លឹប SNYC គួរអានដំបូន្មានសម្រាប់ការរៀបចំនេះ យ៉ាងហោចណាស់មួយសប្តាហ៍មុន

ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំ។

**ការចុះឈ្មោះ**

ចូរពន្យល់ថា អ្នកចូលរួមក្លឹប SNYC ចុះឈ្មោះនៅពេលចាប់ផ្តើមមេរៀននីមួយៗ។ ធ្វើបែបនេះ គឺដើម្បីឲ្យមានការប្តេជ្ញាចិត្ត ហើយក៏ជួយឲ្យអ្នកសម្របសម្រួលក្លឹប SNYC អាចរាប់ដឹងថាតើអ្នកចូលរួមបានចូលរួមប៉ុន្មានម៉ោង ដើម្បីដាក់ពិន្ទុតាមប្រព័ន្ធផ្កាយ (មានពន្យល់ខាងក្រោម)។

**ការពង្រឹងថ្នាក់**

មេរៀននីមួយៗចាប់ផ្តើមដោយល្បែងពង្រឹងថ្នាក់។ល្បែងទាំងនេះបង្កបរិយាកាសរីករាយ ប៉ុន្តែក៏មានគោលបំណងមួយទៀតដែរ គឺវាជួយឲ្យអ្នកចូលរួមជាយុវជនមានអារម្មណ៍ធូរស្រាល និងរីករាយមុនពេលពួកគាត់ចាប់ផ្តើមពិភាក្សាប្រធានបទដែលប្រហែលជាពិបាកក្នុងការពិភាក្សា។ ល្បែងនេះជួយអ្នកចូលរួមឲ្យស្គាល់គ្នា និងជឿជាក់លើគ្នា។វាធ្វើឲ្យអ្នកចូលរួមមានថាមពលនៅពេលចាប់ផ្តើមមេរៀន។អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គឺជាអ្នកដឹកនាំលេងល្បែងនេះ ។ អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC គួរធានាថា ល្បែងនេះមិនប្រើរយៈពេលលើស ១០នាទីឡើយ។

**ការរំឭកឡើងវិញ**

ចូរពន្យល់ថា ការរំឭកឡើងវិញនេះណែនាំអ្នកចូលរួមឲ្យចងចាំអ្វីដែលពួកគាត់បានរៀននៅក្នុងមេរៀនកន្លងទៅ។ ផ្នែកនេះគឺសម្រាប់វាយតម្លៃថាតើអ្នកចូលរួមនៅចងចាំព័ត៌មានទាំងអស់ ហើយកំពុងអនុវត្តព័ត៌មានទាំងនេះក្នុងជីវិតរបស់ពួកគាត់ឬទេ។ វាក៏លើកទឹកចិត្តអ្នកចូលរួមឲ្យផ្សាភ្ជាប់ព័ត៌មានដែលពួកគាត់បានរៀនក្នុងមេរៀនខុសៗគ្នា។

**សៀវភៅកត់ត្រា**

ពន្យល់ថា សៀវភៅកត់ត្រាអាចត្រូវបានប្រើដើម្បីសរសេរ ឬគូររូប។ សៀវភៅណែនាំនេះ ជួយយុវជនក្នុងក្លឹបឲ្យមានការយល់ដឹងអំពីខ្លួនឯងកាន់តែច្រើន គឺជួយឲ្យគាត់ចេះគិតអំពីជីវិតរបស់ពួកគាត់ និងធ្វើការសម្រេចចិត្តដោយសម្បជញ្ញៈ ដើម្បីដឹកនាំជីវិតរបស់ខ្លួនឯង ជៀសវាងការរសាត់អណ្តែតប្រៀបដូចស្លឹកឈើអណ្តែតតាមទឹកហូរ។ សៀវភៅកត់ត្រាក៏ផ្តល់ឲ្យពួកគាត់នូវកន្លែងសម្រាប់បញ្ចេញអារម្មណ៍ដោយគ្មានការវិនិច្ឆ័យ និងការអៀនខ្មាស់។ អ្វីដែលសំខាន់នោះគឺ គ្មានអ្នកណាម្នាក់អាចអានសៀវភៅកត់ត្រារបស់អ្នកចូលរួមបានឡើយ។ ទោះជាអ្នកសម្របសម្រួលក្លឹបSNYCក៏ដោយ ក៏មិនអាចអានសៀវភៅកត់ត្រារបស់អ្នកចូលរួមបានដែរ។ សៀវភៅកត់ត្រានេះគួរតែផ្តល់នូវចន្លោះសម្រាប់កត់ត្រារឿងរ៉ាវផ្ទាល់ខ្លួន។

**ការដើរតួ**

ចូរពន្យល់ថា ការដើរតួក្នុងអំឡុងពេលរៀនមេរៀនមួយចំនួន ត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកចូលរួមឲ្យស្វែងរកប្រធានបទ និងដើម្បីឡើងសម្តែងមតិ។

**ការកំណត់រយៈពេល**

សៀវភៅណែនាំនេះ មានរយៈពេលសមស្របទៅតាមតម្រូវការនៃមេរៀននីមួយៗ។ ហើយអ្វីដែលសំខាន់នោះ គឺត្រូវកំណត់រយៈពេលទៅតាមការគ្រោងទុកសម្រាប់មេរៀននីមួយៗ ដើម្បីកុំឲ្យអ្នកចូលរួមខកខានមិនបានសិក្សាផ្នែកណាមួយ ហើយមេរៀនមិនត្រូវបានដំណើរការលើសពីរយៈពេលដែលបានកំណត់ឡើយ។

**សង្ខេបមេរៀន**

ផ្នែកនេះបង្ហាញអំពីចំណុចសំខាន់ៗនៃមេរៀន។ អ្នកសម្របសម្រួលក្លឹបSNYCត្រូវអានផ្នែកនេះឲ្យឮៗ។ គួរប្រើរយៈពេលតែ១ទៅ៣នាទីប៉ុណ្ណោះ ដើម្បីអានសេចក្តីសង្ខេបមេរៀននេះ។

ប្រាប់អ្នកចូលរួមឲ្យមើលសៀវភៅណែនាំ ហើយរកឧទាហរណ៍បង្ហាញពីលក្ខណៈសំខាន់នីមួយៗដូចខាងក្រោមនេះ។ អានចំណុចនៃលក្ខណៈសំខាន់នោះ ហើយរកអ្នកស្ម័គ្រចិត្តឲ្យឡើងពន្យល់ឮៗអំពីគោលដៅនៃលក្ខណៈសំខាន់ នៅក្នុងល្បះមួយៗ ៖

- វត្ថុបំណង
- សម្ភារៈ
- កិច្ចស្វាគមន៍
- ការល្បែងពង្រឹងថ្នាក់
- ការរំឭកឡើងវិញ
- សង្ខេបមេរៀន
- សៀវភៅកត់ត្រា
- ការដើរតួ

នៅចុងបញ្ចប់នៃការប្រជុំក្លឹប ជាការមានប្រយោជន៍ណាស់ ប្រសិនបើផ្តល់ពេលវេលាឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬអាចផ្តល់យោបល់តបមកវិញ ទៅឲ្យអ្នកសម្របសម្រួល។ សំណួរ ឬយោបល់តបមកវិញទាំងនេះ អាចត្រូវបានប្រមូលយកដោយមិនបាច់ប្រាប់ឈ្មោះ ហើយនឹងធ្វើឲ្យអ្នកសម្របសម្រួលដឹងថា តើត្រូវដោះស្រាយអ្វីខ្លះចំពោះប្រធានបទទាំងនោះ ឬដឹងថាតើត្រូវការការបំភ្លឺបន្ថែមអ្វីខ្លះ។ អ្នកសម្របសម្រួលអាចឆ្លើយតបទៅនឹងការព្រួយបារម្ភ ឬសំណួរនៅក្នុងមេរៀនបន្ទាប់ ឬគ្រោងនឹងឆ្លើយតបនៅពេលក្រោយទៀត។

## កូនសៀវភៅនារីកវៃឆ្លាត

ពន្យល់ថា ឧបករណ៍នារីកវៃឆ្លាតនេះ បានភ្ជាប់ជាមួយកូនសៀវភៅនារីកវៃឆ្លាត។ កូនសៀវភៅ នេះមានទំហំប៉ុនគ្នានឹងលិខិតឆ្លងដែនហើយត្រូវបានបង្កើតឡើងដើម្បីអាចដាក់ចូលក្នុងកាបូបតូចៗ ឬកាបូបលុយ ក្រវ៉ាត់ចង្កេះ។ កូនសៀវភៅនេះ រួមមានព័ត៌មានសំខាន់ដែលត្រូវបានផ្តល់ជាផ្នែកមួយនៃឧបករណ៍នារីកវៃឆ្លាត និងសំខាន់បំផុតគឺ លេខទូរស័ព្ទ និងអាស័យដ្ឋានរបស់ស្ថាប័នដែលគាំទ្រអ្នកធ្វើចំណាកស្រុក។ អ្នកសម្របសម្រួលក្លឹប SNYC ត្រូវប្រាប់អ្នកចូលរួមឲ្យអានកូនសៀវភៅនារីកវៃឆ្លាតរបស់ខ្លួននៅ ពេលណាមួយជាក់លាក់ក្នុងអំឡុងពេលសិក្សាមេរៀនអំពីឧករណ៍នារីកវៃឆ្លាតនេះ។ កូនសៀវភៅនារីកវៃឆ្លាតត្រូវបានរក្សាទុកជាមួយនឹងសៀវភៅកត់ត្រានៅឯក្លឹប SNYC រហូតដល់បញ្ចប់ ការសិក្សាសៀវភៅណែនាំនេះ ដើម្បីកុំឲ្យយុវជនបាត់កូនសៀវភៅរបស់ខ្លួន។

## របៀបដាក់ពិន្ទុតាមប្រព័ន្ធផ្កាយ

ចូរពន្យល់ថាដើម្បីកសាងការប្តេជ្ញាចិត្តនិងជំរុញវត្តមានអ្នកចូលរួមក្លឹបSNYCបានប្រើប្រាស់របៀបដាក់ពិន្ទុតាមប្រព័ន្ធផ្កាយ។ ឧបករណ៍នេះ មាន៣១មេរៀន រាប់បញ្ចូលទាំងមេរៀន ស្តីអំពីកម្មវិធីសកម្មភាពសហគមន៍ផង។ អ្នកចូលរួមទទួលបានផ្កាយ១ដួងសម្រាប់ ម៉ោងរៀននីមួយៗ ដែលពួកគាត់បានចូលរួម។ អ្នកចូលរួមដែលទទួលបាន២២ផ្កាយ មានសិទ្ធិទទួលបាន «រង្វាន់លើកទឹកចិត្តកម្រិត១»។ អ្នកចូលរួមដែលទទួលបាន២៦ផ្កាយ មានសិទ្ធិទទួលបាន«រង្វាន់លើកទឹកចិត្តកម្រិត២» ហើយអ្នកចូលរួមដែលចូលរួមសិក្សាមេរៀនទាំង៣១ មានសិទ្ធិទទួលបាន«រង្វាន់លើកទឹកចិត្តកម្រិត៣»។ អ្នកសម្របសម្រួលជាយុវជនក៏មានសិទ្ធិទទួលបានផ្កាយសម្រាប់ការចូលរួមផងដែរ។ អ្នកសម្របសម្រួលក្លឹប SNYC អាចសម្រេចអំពីមធ្យោបាយដែលពួកគាត់ចង់ចែករំលែក និងបង្ហាញផ្កាយដែលពួកគាត់រកបាន។

ចូរពន្យល់ថា បុគ្គលិកអង្គការទស្សនៈពិភពលោក និងអ្នកសម្របសម្រួលក្លឹប SNYC អាចសម្រេចរួមគ្នាថាតើគួរប្រើប្រាស់របស់អ្វីមកធ្វើជារង្វាន់លើកទឹកចិត្ត។ យោបល់សម្រាប់ជាការលើកទឹកចិត្តអាចមានដូចជា ៖

- វត្ថុដែលបានផ្តល់ជាអំណោយដល់អង្គការទស្សនៈពិភពលោកមានដូចជាសំបុត្រទស្សនាតន្ត្រី ឬអាហារយឺត
- អាហារយឺត ឬម្ហូបក្លឹប SNYC
- ថ្លៃចំណាយសម្រាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងប្រធានបទដែលទាក់ទងនឹងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព
- ចូលរួមកម្មវិធី ឬការប្រារព្ធពិធីប្រឆាំងការជួញដូររបស់អង្គការទស្សនៈពិភពលោកប្រចាំតំបន់

ក្លឹប SNYC នីមួយៗ នឹងមានរង្វាន់ខុសៗគ្នា ។

## ការអនុវត្តតាមសេចក្តីណែនាំរបស់ឧបករណ៍នារីកវៃឆ្លាត

ចូរពន្យល់ថា អង្គការទស្សនៈពិភពលោកលើកទឹកចិត្តដល់អ្នកសម្រលសម្រួលឲ្យនាំយកគំនិត និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ មកកាន់ក្លឹប SNYC ហើយផ្សាភ្ជាប់មេរៀនទៅនឹងភាពពិតជាក់ស្តែងនៅក្នុងសហគមន៍របស់ពួកគាត់។ នៅពេលជាមួយគ្នានេះដែរអ្នកសម្របសម្រួលចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំក្នុងឧបករណ៍នារីកឆ្លាតនេះ។ អ្នកសម្របសម្រួលក្លឹប SNYC គួរយកឧបករណ៍នារីកវៃឆ្លាតមកគ្រប់ម៉ោងរៀន ហើយអនុវត្តតាមជំហានដែលពួកគាត់បានបង្រៀន។ អ្នកសម្របសម្រួលក្លឹប SNYC គួរអានសៀវភៅណែនាំនោះពេញម៉ោងរៀន ពីព្រោះព័ត៌មាននៅក្នុងសៀវភៅណែនាំនោះគឺជាក់លាក់ណាស់ (ឧទាហរណ៍និយមន័យនៃការជួញដូរលេខទូរស័ព្ទពេលមានអាសន្ន និងច្បាប់ស្តីពីការជួញដូរ)។

អ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់ត្រូវអនុវត្តតាមសេចក្តីណែនាំក្នុងឧបករណ៍នារីកវៃឆ្លាតនេះ។

## ការពិចារណាដទៃទៀត

### យុវជនមិនអាចអានបាន

ពន្យល់ថាក្លឹប SNYC មានគោលដៅផ្តោះទៅរកយុវជនងាយរងគ្រោះ។ ក្នុងចំណោមយុវជនទាំងនេះមានយុវជនខ្លះ ដែលជំនាញអក្ខរភាពរបស់ពួកគាត់នៅមានកម្រិត។ឧបករណ៍នារីកវៃឆ្លាតត្រូវបានបង្កើតឡើងសម្រាប់យុវជនដែលចេះអាន។ ឧបករណ៍នារីកវៃឆ្លាតនេះនឹងត្រូវកែសម្រួលជាចាំបាច់ប្រសិនបើក្លឹបSNYCមានភាគរយខ្ពស់នៃអ្នកមិនអាចអានអក្សរបាន។ ទោះជាយ៉ាងណា ក៏ដោយក្លឹប SNYC អាចបញ្ចូលយុវជនមិនចេះអក្សរប្រហែលជា២០ភាគរយប្រសិនបើ ចាំបាច់។ ប្រសិនបើក្លឹប SNYC មានអ្នកចូលរួមជាយុវជនដែលមិនចេះអានបានសូមប្រើបញ្ជីត្រួតពិនិត្យដើម្បីធានាជួយសម្រួលដល់ អ្នកចូលរួមទាំងនេះ ៖

- កុំប្រាប់ក្រុមទាំងមូលថា អ្នកចូលរួមណាខ្លះដែលមិនអាចអានអក្សរបាន
- នៅពេលចែកព័ត៌មានជាអក្សរដល់អ្នកចូលរួម (ឧទាហរណ៍ ប័ណ្ណព័ត៌មាន) ចាំបាច់ត្រូវ អានព័ត៌មាននោះឮៗ ដើម្បីឲ្យអ្នកចូលរួមដែលមិនអាន អាចឮ និងយល់បាន។
- នៅពេលអ្នកសម្របសម្រួលក្លឹប SNYC បែងចែកអ្នកចូលរួមជាក្រុមដើម្បីអនុវត្តសកម្មភាព លើផ្ទាំងក្រដាសផ្លិបឆាត ឬដើម្បីពិភាក្សាបញ្ហានានានោះ ចាំបាច់ត្រូវបែងចែកយុវជនដែលមិនចេះអាននៅក្នុងក្រុមអ្នកអាចអក្សរបាន ដើម្បីឲ្យយុវជនដែលអាចអក្សរបាន អាចសរសេរឲ្យពួកគាត់បាន ។
- ឧបករណ៍នារីកវៃឆ្លាតនេះផ្តល់ឱកាសច្រើនដល់អ្នកចូលរួមដើម្បីគូររូបភាពបង្ហាញពីបទពិសោធន៍របស់ពួកគាត់។ អ្នកសម្របសម្រួលក្លឹប SNYC គួរសង្កត់ធ្ងន់ថាពួកគាត់មានជ្រើសនៅក្នុងការគូររូប (ឧទាហរណ៍ ក្នុងម៉ោងសិក្សាអំពីសៀវភៅកត់ត្រា)

- ប្រសិនបើសកម្មភាពពាក់ព័ន្ធការហុចតគ្នានូវថង់មួយដែលមានព័ត៌មានសរសេរនៅលើក្រដាស អ្នកសម្របសម្រួលក្លឹប SNYC គួរធានាថាថង់មិនឈប់នៅត្រង់អ្នកចូលរួមដែលមិនអាចអក្សរបានទេ។
- សម្រាប់សកម្មភាពភាគច្រើនតម្រូវឲ្យយុវជនធ្វើការជាគូ ឬជាក្រុមដើម្បីឲ្យយុវជនដែលមិនអាចអក្សរបាន អាចធ្វើការជាមួយយុវជនដែលអាចអានអក្សរបាន។

## សង្ខេបមេរៀន

- ឧបករណ៍នារីកវែឆ្លាតនេះ មានប្រាំមួយផ្នែក។
- ផ្នែកនីមួយៗមានមេរៀនក្នុងលក្ខណៈជាកិច្ចតែងការបង្រៀនដែលមានរយៈពេលប្រហែល ៧៥នាទី។
- អ្នកចូលរួមក៏ទទួលបានកូនសៀវភៅនារីកវែឆ្លាតដែលសង្ខេបប្រធានបទសំខាន់ៗបំផុតនៅក្នុងឧបករណ៍នារីកឆ្លាត។
- អ្នកចូលរួមនីមួយៗទទួលបានផ្កាយ១ដួងសម្រាប់ម៉ោងរៀននីមួយៗដែលខ្លួនបានចូលរួម។ ផ្កាយត្រូវបានបូក បញ្ចូលគ្នាដើម្បីទទួលបានរង្វាន់។
- ក្លឹប SNYC អាចទទួលយកអ្នកចូលរួមជាយុវជនដែលមិនអាចអានបានក្នុងចំនួនតិចតួច ដោយប្រើប្រាស់ជំហានដែលរៀបរាប់ខាងលើ។
- អ្នកសម្របសម្រួលក្លឹប SNYC គួរអនុវត្តតាមសេចក្តីណែនាំក្នុងឧបករណ៍នារីកវែឆ្លាត។

## យុវជនដែលរស់នៅបែកពីឪពុកម្តាយ

ក្លឹប SNYC ត្រូវបានបង្កើតឡើងដើម្បីកសាងទំនាក់ទំនងក្នុងចំណោមយុវជន ឪពុកម្តាយរបស់ពួកគាត់ និងសហគមន៍មូលដ្ឋាន ដោយមានជំនឿថាការធ្វើដូច្នេះអាចពង្រឹងការសិក្សារៀនសូត្រ និងកសាងការប្តេជ្ញាចិត្តចំពោះក្លឹបបាន។ ទោះជាយ៉ាងណាក៏ដោយក្នុងករណីមួយចំនួនក្លឹប SNYC អាចធ្វើការជាមួយយុវជនដែលមិនរស់នៅជាមួយឪពុកម្តាយគាត់។ ក្នុងករណីទាំងនេះអ្នកសម្របសម្រួលក្លឹប SNYC គួរលុបចោលផ្នែកខ្លះក្នុងឧបករណ៍នារីកវែឆ្លាតនេះ គឺផ្នែក ដែលតម្រូវឲ្យយុវជនពិភាក្សាបញ្ហានានាជាមួយឪពុកម្តាយ។ ប្រសិនបើសក្តិសមអ្នកសម្របសម្រួលគួរប្រាប់យុវជនឲ្យពិភាក្សាបញ្ហាទាំងនេះជាមួយមនុស្សពេញវ័យដែលខ្លួនជិតស្និទ្ធ ជាមួយមេដឹកនាំសាសនា ឬមិត្តភក្តិរបស់ពួកគាត់ជំនួសឲ្យឪពុកម្តាយវិញ។

## ប័ណ្ណព័ត៌មានលេខ ៣ក ៖ យុវជនអាចអានបាន

ឧបករណ៍នារីកវៃឆ្លាតនេះ ត្រូវបានបង្កើតឡើងដើម្បីបង្រៀនយុវជនដែលអាចអានអក្សរបាន។ ចាំបាច់ត្រូវកែសម្រួលសៀវភៅនេះ ប្រសិនបើក្លឹប SNYC មួយមានយុវជនមិនអាចអានអក្សរច្រើននាក់។ ទោះជាយ៉ាងណាក៏ដោយ ក្លឹប SNYC អាចបញ្ចូលយុវជនដែលមិនអាចអានអក្សរបានប្រមាណ ជា២០ភាគរយ ប្រសិនបើចាំបាច់។ បើក្លឹប SNYC មានអ្នកចូលរួម ជាយុវជនមិនចេះអក្សរ ចូរប្រើប្រាស់យោបល់ខាងក្រោមនេះ ដើម្បីធានាជួយសម្រួលដល់អ្នកចូលរួម ៖

- កុំប្រាប់ក្រុមទាំងមូលថា អ្នកចូលរួមណាខ្លះដែលមិនចេះអាន
- នៅពេលចែកព័ត៌មានជាអក្សរដល់អ្នកចូលរួម (ឧទាហរណ៍ ប័ណ្ណព័ត៌មាន) ចាំបាច់ត្រូវ អានព័ត៌មាននោះឮៗ ដើម្បីឲ្យអ្នកចូលរួមដែលមិនចេះអាន អាចឮ និងយល់បាន។
- នៅពេលអ្នកសម្របសម្រួលក្លឹប SNYC បែងចែកអ្នកចូលរួមជាក្រុម ដើម្បីអនុវត្តសកម្មភាពលើផ្ទាំងក្រដាសហ្វ្លីបឆាត ឬដើម្បីពិភាក្សាបញ្ហានានានោះ ចាំបាច់ត្រូវបែងចែកយុវជនដែលមិនចេះអាននៅក្នុងក្រុមអ្នកចេះអក្សរ ដើម្បីឲ្យយុវជនដែលចេះអក្សរ អាចសរសេរឲ្យពួកគាត់បាន ។
- ឧបករណ៍នារីកវៃឆ្លាតនេះផ្តល់ឱកាសច្រើនដល់អ្នកចូលរួម ដើម្បីគូររូបភាពបង្ហាញពីបទពិសោធន៍របស់ពួកគាត់។ អ្នកសម្របសម្រួលក្លឹប SNYC គួរសង្កត់ធ្ងន់ថា ពួកគាត់មានជ្រើសនៅក្នុងការគូររូប (ឧទាហរណ៍ក្នុងម៉ោងសិក្សាអំពីសៀវភៅកត់ត្រា)
- ប្រសិនបើសកម្មភាពពាក់ព័ន្ធការហុចតគ្នានូវកាបូបមួយដែលមានព័ត៌មានសរសេរនៅលើក្រដាស អ្នកសម្របសម្រួលក្លឹប SNYC គួរធានាថាកចង់មិនឈប់នៅត្រង់អ្នកចូលរួមដែលមិនអាចអានអក្សរបានទេ។
- សម្រាប់សកម្មភាពភាគច្រើនតម្រូវឲ្យយុវជនធ្វើការជាគូ ឬជាក្រុមដើម្បីឲ្យយុវជនដែលមិនអាចអានអក្សរបាន អាចធ្វើការជាមួយយុវជនដែលអាចអានអក្សរបាន។

# មេរៀនទី៤ ៖ ត្រួតពិនិត្យឧបករណ៍នាវិកវៃឆ្លាត

## វត្ថុបំណង

អ្នកចូលរួម នឹងយល់ដឹងអំពីសារៈសំខាន់នៃបែបបទត្រួតពិនិត្យខ្លួនឯងការគ្រប់គ្រង និងថ្លៃវាយតម្លៃ។ អ្នកចូលរួមនឹងយល់អំពីលក្ខណៈវិនិច្ឆ័យសំខាន់ៗ ដែលនឹងត្រូវប្រើប្រាស់សម្រាប់វាយតម្លៃទៅលើក្លឹប SNYC និងសៀវភៅណែនាំ នៅពេលបញ្ចប់។

## រយៈពេល

៦០ នាទី

## សម្ភារ

- ឯកសារថតចម្លង នៃសៀវភៅណែនាំសម្រាប់អ្នកចូលរួមនីមួយៗ
- សៀវភៅកត់ត្រារបស់អ្នកចូលរួម

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យពី២ ទៅ៣ រូប មកពីក្លឹប SNYC នីមួយៗ

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្តុះបណ្តាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP។

## សេចក្តីណែនាំ

ចូរពន្យល់ថា មេរៀននេះនឹងពន្យល់អំពីរបៀបប្រមូលព័ត៌ក្លឹប SNYC និងឧបករណ៍នាវិកវៃឆ្លាត។ ការប្រមូលព័ត៌នេះអាចជួយអង្គការទស្សនៈពិភពលោកឲ្យយល់ដឹងអំពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់សៀវភៅណែនាំ និងក្លឹប SNYC ដើម្បីអាចធ្វើឲ្យឧបករណ៍នាវិកវៃឆ្លាត និងក្លឹប SNYC មានភាពកាន់តែប្រសើរឡើង ។

ប្រាប់អ្នកចូលរួមឲ្យអានបែបបទត្រួតពិនិត្យខ្លួនឯងនៅក្នុងសៀវភៅណែនាំរបស់ពួកគាត់ នៅទំព័រទី៧។

## បែបបទត្រួតពិនិត្យខ្លួនឯង

បែបបទត្រួតពិនិត្យខ្លួនឯង ត្រូវបានបញ្ចូលនៅពេលចាប់ផ្តើមឧបករណ៍នារីកវៃឆ្លាត។ អ្នកសម្របសម្រួលជាមនុស្សពេញវ័យគួរបំពេញបែបបទទាំងនេះក្រោយពេលបញ្ចប់ មេរៀននីមួយៗ ហើយរក្សាបែបបទទាំងនេះទុកនៅក្នុងប្រអប់ចាក់សោរជាមួយនឹងសៀវភៅកត់ត្រា និងក្រដាសចុះឈ្មោះ។

បែបបទត្រួតពិនិត្យខ្លួនឯង អាចឲ្យអ្នកសម្របសម្រួលក្លឹប SNYC បង្ហាញពីអ្វីដែលបានកើតឡើងក្នុងម៉ោងរៀនហើយថែមទាំងបន្ថកសាងចំណុចខ្លាំងនានានិងអាចធ្វើការកែសម្រួលបាននៅពេលមានបញ្ហាប្រឈមផ្សេងៗ។ អ្នកសម្របសម្រួលក្លឹប SNYC ត្រូវបានលើកទឹកចិត្តឲ្យមានភាពស្មោះត្រង់។ បែបបទទាំងនេះមិនមែនជាការសាកល្បងទេ ប៉ុន្តែជាឧបករណ៍ដែលអ្នកសម្របសម្រួលក្លឹប SNYC អាចប្រើប្រាស់ដើម្បីអភិវឌ្ឍខ្លួនឯង។ ប្រសិនបើប្រើប្រាស់បានល្អបែបបទទាំងនេះអាចផ្តល់ភាពកាន់តែងាយស្រួលដល់ការងាររបស់អ្នកសម្របសម្រួលក្លឹបSNYCដោយធ្វើឲ្យក្លឹបដំណើរការកាន់តែរលូនល្អ។ បែបបទទាំងនេះក៏អាចឲ្យអ្នកសម្របសម្រួលកត់ត្រាបញ្ហានានាដែលបានជួបប្រទះនៅក្នុងការបង្រៀនអំពីឧបករណ៍នារីកវៃឆ្លាតដែរ ដើម្បីឲ្យអ្នកសម្របសម្រួលទាំងនោះអាចចែករំលែកបញ្ហាទាំងនោះជាមួយនឹងសមាជិកបុគ្គលិកអង្គការទស្សនៈពិភពលោកបាន។

សួរទៅអ្នកចូលរួម ៖

- តើអ្នកគិតថាសំណួរទាំងនេះនឹងជួយធ្វើឲ្យក្លឹប SNYC មានភាពប្រសើរជាងមុន ឬទេ?
- តើឧបសគ្គអ្វីដែលអាចមានចំពោះការប្រើប្រាស់បែបបទទាំងនេះ?
- តើអ្នកអាចជំនះឧបសគ្គទាំងនេះដោយរបៀបណា?
- តើអ្នកគិតថាគួរប្រើពេលប៉ុន្មានដង ដើម្បីបំពេញបញ្ចប់បែបបទទាំងនេះ?

## ការគ្រប់គ្រង

អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ខិតខំធ្វើការយ៉ាងខ្លាំងក្នុងការគ្រប់គ្រងដំណើរការក្លឹបSNYCហើយឧបករណ៍នារីកវៃឆ្លាតនេះអាចនាំឲ្យមានបញ្ហាប្រឈមនានាពិសេសសម្រាប់អ្នកសម្របសម្រួលក្លឹប SNYC។ ចូរពន្យល់ថា បុគ្គលិកអង្គការទស្សនៈពិភពលោកនឹងផ្តល់ការគ្រប់គ្រងចំពោះអ្នកសម្របសម្រួល ក្លឹប SNYC។ បុគ្គលិកអង្គការទស្សនៈពិភពលោកនឹងឲ្យលេខទូរស័ព្ទរបស់ខ្លួនទៅអ្នកសម្របសម្រួលក្លឹប SNYC ហើយលើកទឹកចិត្តឲ្យគាត់ទូរស័ព្ទមកខ្លួន ក្នុងករណីអ្នកសម្របសម្រួលទាំងនោះជួបប្រទះបញ្ហា ឬមានសំណួរផ្សេងៗ។ បុគ្គលិកអង្គការទស្សនៈពិភពលោកក៏នឹងទូរស័ព្ទមកអ្នកសម្របសម្រួលក្លឹប SNYC ពីរដងក្នុងមួយខែ ដើម្បីពិភាក្សាអំពីដំណើរការទៅមុខ និងបញ្ហានានា។ បុគ្គលិកទស្សនៈពិភពលោក ក៏នឹងរៀបចំកម្មវិធីជួបជុំជាមួយនឹងអ្នកសម្របសម្រួលក្លឹប SNYC រៀងរាល់ពីរខែម្តងដើម្បីផ្តល់ការគ្រប់គ្រង និងការគាំទ្រ។

## ថ្ងៃវាយតម្លៃ

បុគ្គលិកអង្គការទស្សនៈពិភពលោក ក៏នឹងដឹកនាំសិក្ខាសាលារយៈពេលមួយថ្ងៃដើម្បីធ្វើការវាយតម្លៃ ដែលមានលក្ខណៈជាការផ្តល់ឱកាសឲ្យចូលរួម និងមិនប៉ះពាល់ដល់ យុវជននៅចុងបញ្ចប់នៃឧបករណ៍នារីកវៃឆ្លាត។

បុគ្គលិកអង្គការទស្សនៈពិភពលោក នឹងផ្តល់ឧបករណ៍វាយតម្លៃ ដែលសមស្របមានលក្ខណៈជាការផ្តល់ឱកាសឲ្យចូលរួម ហើយមិនប៉ះពាល់ដល់យុវជនសម្រាប់យកទៅប្រើប្រាស់នៅថ្ងៃនោះ។

### ភាគីពាក់ព័ន្ធ

គួរអញ្ជើញមនុស្សដូចខាងក្រោមឲ្យមកចូលរួម ៖

- អ្នកសម្របសម្រួលជាមនុស្សពេញវ័យ
- អ្នកសម្របសម្រួលជាយុវជន
- អ្នកចូលរួមជាយុវជនក្នុងក្លឹប SNYC

មនុស្សទាំងនេះ គួរផ្តុំជាក្រុមដាច់ដោយឡែកគ្នា ដើម្បីវាយតម្លៃក្លឹប SNYC និងឧបករណ៍នារីកឆ្លាត។

### អ្នកចូលរួមជាយុវជន និងអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC

ឧបករណ៍សម្រាប់យុវជន វាយតម្លៃកំណើនចំណេះដឹងស្តីអំពី ៖

- ការជួញដូរ
- កលល្បិចទូទៅរបស់អ្នកជួញដូរ
- ច្បាប់ប្រឆាំងការជួញដូរមនុស្សនិង សិទ្ធិមនុស្ស
- ការរើសអើងយេនឌ័រ និងការជួញដូរ
- គ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង និងការជួញដូរ
- ទំនាក់ទំនងដោយស្មោះត្រង់
- ពូកែស្តាប់
- គ្រប់គ្រងអារម្មណ៍មិនល្អ
- ការសម្រេចចិត្តត្រឹមត្រូវ
- ឯកសារ និងព័ត៌មានដែលត្រូវយកទៅតាមខ្លួន ប្រសិនបើអ្នកគ្រោងនឹងធ្វើចំណាកស្រុក
- របៀបរក្សាសុវត្ថិភាពនៅពេលធ្វើដំណើរ
- របៀបរក្សាសុវត្ថិភាពនៅពេលទៅដល់
- កិច្ចការដែលគួរធ្វើ ប្រសិនបើអ្នកត្រូវបានគេជួញដូរ

ឧបករណ៍សម្រាប់យុវជន នឹងវាយតម្លៃការផ្លាស់ប្តូរឥរិយាបទ និងអាកប្បកិរិយារបស់យុវជនជាពិសេស៖

- ថាតើយុវជនគ្រោងនឹងពន្យារការធ្វើចំណាកស្រុក ឬទេ
- ថាតើយុវជននឹងប្រើប្រាស់ព័ត៌មាននៅក្នុងឧបករណ៍នារីកវៃឆ្លាតនេះ( ដូចជាបញ្ជីត្រួតពិនិត្យ ) ដើម្បីរៀបចំ ផែនការសម្រាប់ការធ្វើចំណាកស្រុក ឬទេ - ហេតុអ្វីបានជាប្រើ ឬហេតុអ្វីបានជាមិនប្រើ ?
- ថាតើយុវជនជឿថាពួកគាត់បានបង្កើនជំនាញ តាមរយៈក្លឹប SNYC នេះ ឬទ ?
- ឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាននៃក្លឹប SNYC ទៅលើជីវិតរបស់យុវជន

### អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC

ឧបករណ៍សម្រាប់អ្នកសម្របសម្រួលជាមនុស្សពេញវ័យនឹងៈ

- ធ្វើឲ្យយើងស្គាល់អំពីចំណុចជោគជ័យរបស់ក្លឹប SNYC
- កំណត់បញ្ហាប្រឈមដែលក្លឹប SNYC ជួបប្រទះ និងរបៀបដោះស្រាយបញ្ហាទាំងនេះ
- វាយតម្លៃគុណភាពនៃការសម្របសម្រួល នៅក្នុងជំនាញបង្រៀន និងចំណេះដឹង

ជាចុងក្រោយ អ្នកសម្របសម្រួល និងយុវជន គួរចូលរួមចំណែកក្នុងការវាយតម្លៃដំណើរការនៃក្លឹប SNYC ក្នុងនោះ មានៈ

- កម្រិតវត្តមាន
- កត្តាដែលប៉ះពាល់ដល់កម្រិតវត្តមាន
- តើយុវជនរីករាយជាមួយក្លឹប ឬទេ ? ហើយបើមិនរីករាយទេ សូមបង្ហាញពីមូលហេតុ។
- តើក្លឹប SNYC បញ្ចូលមនុស្សគ្រប់ស្រទាប់វណ្ណៈ ឬអត់ ?
- គុណភាពនៃការសម្របសម្រួល
- ចំណុចជោគជ័យនៃ SNYC
- បញ្ហាប្រឈមរបស់ក្លឹប SNYC

### វិធីសាស្ត្រ

ឧបករណ៍ដែលត្រូវបានប្រើជាមួយមនុស្សពេញវ័យ និងយុវជននឹងមានលក្ខណៈជាការចូលរួមមានន័យថា ឧបករណ៍ទាំងនេះនឹងលើកទឹកចិត្តអ្នកចូលរួមជួយផ្តល់ជាគំនិត និងផ្សេងៗមិនមែនត្រឹមតែផ្តល់ព័ត៌មានពិតប៉ុណ្ណោះទេ។

ឧបករណ៍ដែលត្រូវប្រើជាមួយយុវជន គឺមិនប៉ះពាល់ដល់កុមារទេ ( ប្រើប្រាស់សកម្មភាពដែលយុវជនចូលចិត្តធ្វើ ដូចជា គូររូបដើម្បីសម្តែងមតិរបស់ពួកគាត់ ) ។

បុគ្គលិកអង្គការទស្សនៈពិភពលោក នឹងដាក់បញ្ចូលលទ្ធផលនៃការវាយតម្លៃក្នុងការធ្វើផែនការអនាគតសម្រាប់ក្លឹប SNYC ហើយនឹងកែសម្រួលឧបករណ៍នារីកឆ្លាតសម្រាប់ប្រើប្រាស់ក្នុងពេលអនាគត។

## សកម្មភាព ៖ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនលើការផ្លាស់ប្តូរអាកប្បកិរិយា

ចូរប្រាប់អ្នកចូលរួមឲ្យយកសៀវភៅកត់ត្រារបស់ពួកគាត់ចេញមក។ ចូរឲ្យពួកគាត់សរសេរ ឬគូរនៅក្នុងសៀវភៅកត់ត្រានោះអំពីពេលមួយដែលពួកគាត់បានផ្លាស់ប្តូរទស្សនៈរបស់គាត់ស្តីពីអ្វីមួយ ឬផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគាត់ (ឧទាហរណ៍ នៅពេលពួកគាត់ឈប់ជក់បារី គាត់ចាប់ផ្តើមស្លៀកពាក់ដូចមនុស្សជំទង់ចាប់ផ្តើមរៀនភាសាអង់គ្លេសសម្រេចចិត្តរៀនបើកបរ សម្រេចចិត្តធ្វើការជាមួយយុវជនងាយរងគ្រោះ)។

ចូរប្រាប់ពួកគាត់ឲ្យពិចារណាថា តើអ្វីខ្លះជាឥទ្ធិពល ដែលធ្វើឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយាបែបនេះ។ សួរថា «តើជាគ្រួសារ មិត្តភក្តិ ចំណេះដឹងថ្មី កាលៈទេសៈជីវិត ការភ័យក្លាចមហិច្ឆតា ក្តីសង្ឃឹម ឬអ្វីក្រៅពីនេះ ដែលធ្វើឲ្យគាត់មានការផ្លាស់ប្តូរទាំងស្រុងបែបនេះ? ពួកគាត់ នឹងមានរយៈពេលប្រហែល១០នាទីដើម្បីសរសេរ។

បន្ទាប់មក ចូរប្រាប់ពួកគាត់ឲ្យចែកគ្នាជាក្រុមមានគ្នាពី៦ទៅ៨នាក់។ ប្រាប់ក្រុមនីមួយៗឲ្យបង្កើតបញ្ជីពីរ ៖

- កត្តាខាងក្នុងដែលបណ្តាលឲ្យមនុស្សផ្លាស់ប្តូរអាកប្បកិរិយា
- កត្តាខាងក្រៅដែលបណ្តាលឲ្យមនុស្សផ្លាស់ប្តូរអាកប្បកិរិយា

បន្ទាប់មក ចូរប្រាប់ឲ្យពួកគាត់ពិចារណា ៖

- ជាធម្មតា តើការផ្លាស់ប្តូរអាកប្បកិរិយា គឺបណ្តាលមកពីឥទ្ធិពលតែមួយ ឬឥទ្ធិពលច្រើន?
- តើមានផ្នែកមួយណានៅក្នុងបញ្ជី ដែលអ្នកសម្របសម្រួលក្លឹប SNYC អាចប្រើប្រាស់បាន ឬទេ?

ប្រាប់ក្រុមឲ្យពន្យល់អំពីចម្លើយរបស់ខ្លួន។ រំឭកអ្នកចូលរួមថា ប្រសិនបើពួកគាត់គិតថាលទ្ធផលណាមួយ ដែលចេញមកពីសកម្មភាពនេះ អាចមានសារៈប្រយោជន៍ក្នុងការងាររបស់ពួកគាត់ ចូរឲ្យពួកគាត់គូរកត់ត្រាទុកនៅក្នុងផ្នែកចុងក្រោយនៃឧបករណ៍នារីកវៃឆ្លាត។

**សង្ខេបមេរៀន**

- អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC គួរបំពេញបែបបទត្រួតពិនិត្យខ្លួនឯង ក្រោយពេលបញ្ចប់មេរៀននីមួយៗ ហើយរក្សាបែបបទទាំងនេះទុកនៅក្នុងប្រអប់ចាក់សោរទុកជាមួយសៀវភៅកត់ត្រា និងក្រដាសចុះឈ្មោះ។
- បុគ្គលិកអង្គការនឹងផ្តល់ការគ្រប់គ្រងចំពោះអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ដោយលើកទឹកចិត្ត អ្នកសម្របសម្រួលទាំងនោះឲ្យទូរសព្ទមកខ្លួន ប្រសិនបើពួកគាត់ជួបបញ្ហា ហើយមកជួបប្រជុំជាមួយអ្នកសម្របសម្រួលក្លឹប SNYC រៀងរាល់ពីរខែម្តង។
- បុគ្គលិកអង្គការទស្សនៈពិភពលោក នឹងដឹកនាំសិក្ខាសាលាវាយតម្លៃរយៈពេលមួយថ្ងៃនៅចុងបញ្ចប់នៃ ឧបករណ៍នារីកវៃឆ្លាតសម្រាប់អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC។
- ក្រុមវាយតម្លៃ និងត្រួតពិនិត្យរបស់អង្គការទស្សនៈពិភពលោក នឹងផ្តល់ឧបករណ៍ដែលបានរៀបចំរួច ដើម្បីវាយតម្លៃលើចំណុចខាងក្រោម នៅក្នុងសិក្ខាសាលានេះ៖
  - ចំណេះដឹង
  - ការផ្លាស់ប្តូរអាកប្បកិរិយា
  - ដំណើរការក្លឹប SNYC
- ឧបករណ៍វាយតម្លៃ គឺត្រូវមានលក្ខណៈជាការផ្តល់ឱកាសឲ្យចូលរួម និងមិនប៉ះពាល់ដល់កុមារ។

# ផ្នែក គ

# ជំនាញសម្របសម្រួល



# មេរៀនទី៥ ៖ ទំនាក់ទំនងជាមួយយុវជន

## វត្ថុបំណង

អ្នកចូលរួមនឹងយល់ដឹងថា ការយល់អំពីការអភិវឌ្ឍន៍របស់យុវជន ការកសាងទំនាក់ទំនងល្អ និងការដឹងអំពីកម្រិតរបស់ខ្លួន គឺជាជំនាញដ៏សំខាន់សម្រាប់អ្នកសម្របសម្រួលក្លឹប SNYC ។

## រយៈពេល

៣០ នាទី

## សម្ភារ

- ឯកសារថតចម្លងនៃឧបករណ៍នាវិកផ្លាតសម្រាប់អ្នកចូលរួមនីមួយៗ
- ឯកសារថតចម្លងនៃ
  - » ប័ណ្ណព័ត៌មានលេខ ៥ក ៖ ករណីសិក្សា តារាង១
  - » ប័ណ្ណព័ត៌មានលេខ ៥ខ ៖ ករណីសិក្សា តារាង២ សម្រាប់ក្លឹប SNYC នីមួយៗ

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ ២-៣ រូប មកពីក្លឹប SNYC នីមួយៗ

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្តុះបណ្តាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP ។

## សេចក្តីណែនាំ ៖ ការអភិវឌ្ឍ ទំនាក់ទំនង និង កម្រិតយល់ដឹង

អានផ្នែកខាងក្រោមនេះឲ្យឮៗដល់ក្រុម ។ លើកទឹកចិត្តឲ្យអ្នកចូលរួមសួរសំណួរនៅពេលដែលអ្នកកំពុង អានបន្ត ។

## ស្វែងយល់អំពីការអភិវឌ្ឍន៍របស់ក្មេងជំទង់

ចូរពន្យល់ថា ក្មេងជំទង់ឆ្លងកាត់ការផ្លាស់ប្តូរធំៗនៅក្នុងជីវិតរបស់គាត់ចន្លោះអាយុពី១២ ទៅ១៧ឆ្នាំ។ ដងខ្លួនរបស់ពួកគាត់មានសភាពប្រែប្រួល ហើយនៅពេលកំពុងមានការប្រែប្រួល ពួកគាត់ទទួលអារម្មណ៍ខ្លាំងក្លា ដោយសារអ័រម៉ូនដែលបង្កឲ្យមានសភាពប្រែប្រួល។ ថ្ងៃមួយ ពួកគាត់អាចសប្បាយចិត្ត នៅថ្ងៃបន្ទាប់ ពួកគាត់អាចពិបាកចិត្តខ្លាំង ហើយមានក្តីស្រលាញ់ នៅថ្ងៃបន្ទាប់ទៀត។ ក្មេងជំទង់ក៏ជួបប្រទះនូវ អារម្មណ៍ស្មុគស្មាញ ពីព្រោះពួកគាត់កំពុងត្រៀម ខ្លួនដើម្បីទទួលខុសត្រូវលើជីវិតខ្លួនឯងផ្ទាល់។ ជាធម្មតា ពួកគាត់ចង់មានឯករាជ្យ ប៉ុន្តែព្រួយ បារម្ភថាតើនឹងគាំទ្រខ្លួនឯងដោយរបៀបណា ប្រសិនបើពួកគាត់នឹងមានស្នេហា ឬប្រសិនបើ ពួកគាត់នឹងកសាងគ្រួសារផ្ទាល់ខ្លួននោះ។ ក្មេងជំទង់ មានលក្ខណៈស្មុគ្រស្មាញណាស់។

ដើម្បីធ្វើជាអ្នកសម្របសម្រួលក្លឹប SNYC ដ៏ល្អមួយរូប ត្រូវយល់ពីអារម្មណ៍ខ្លាំងក្លារបស់ ក្មេងជំទង់ ហើយត្រូវស្តាប់ដោយមិនវាយតម្លៃគាត់ ឬ សើចអំអកឲ្យគាត់ឡើយ។

### ចូរកសាងទំនាក់ទំនង

ចូរប្រាប់អ្នកចូលរួម ឲ្យគិតត្រឡប់ទៅពេលដែលពួកគាត់នៅសាលារៀន។ សួរថា «តើមាន គ្រូណា ដែលអ្នកចូលចិត្តជាង ឬទេ? តើមានគ្រូណាម្នាក់ដែលអ្នកនៅតែគិតដល់គាត់ រហូតដល់ ពេលបច្ចុប្បន្ននេះ ហើយ ដែលមានឥទ្ធិពលវិជ្ជមានលើការសិក្សារបស់អ្នក ឬទេ? ប្រាប់អ្នកចូលរួម ឲ្យបិទភ្នែករយៈពេលមួយនាទី ហើយគិតអំពីគ្រូម្នាក់នោះ។

ឥឡូវ សួរថាតើអ្នកចូលរួមមានទំនាក់ទំនងល្អជាមួយគ្រូម្នាក់នោះដែរឬទេ។ ការបង្រៀន ល្អមិនគ្រាន់តែរាប់បញ្ចូលការដឹងអំពីប្រធានបទប៉ុណ្ណោះទេ វាក៏ពាក់ព័ន្ធនឹងការកសាងទំនាក់ទំនង ផងដែរ។ អ្នកសម្របសម្រួលក្លឹប SNYC គួរព្យាយាមរកអ្វីដែលពួកគាត់ចូលចិត្តអំពីសមាជិក នីមួយៗនៃក្លឹប SNYC។ អ្នកសម្របសម្រួល គួរព្យាយាមរៀនសូត្រ អំពីគ្រួសាររបស់យុវជន និង ចងចាំឈ្មោះរបស់មិត្តភក្តិរបស់ពួកគាត់ ។

ចូរពន្យល់ថា អ្នកសម្របសម្រួលក្លឹប SNYC គួរនៅចាំក្នុងក្លឹប SNYC រយៈពេល១០នាទី ក្រោយពេលចប់មេរៀន ហើយត្រូវរំឭកដល់ យុវជនថា ពួកគាត់អាចប្រើពេលវេលានោះ ដើម្បីពិភាក្សាជាមួយអ្នកសម្របសម្រួលបាន ប្រសិនបើពួកគាត់ត្រូវការ។ ប្រសិនបើអ្នក ចូលរួមក្លឹប SNYC ហាក់ដូចជាខកចិត្តនោះ អ្នកសម្របសម្រួលក្លឹប SNYC គួរសួរថា តើអ្នកចូលរួមចង់មានយោបល់អ្វី ឬទេ។ ទោះជាយ៉ាងណា សូមចាំថា ដោយសារតែ វិន័យការពារកុមារ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរនៅ តែពីរនាក់តទល់នៅក្នុង បន្ទប់មួយជាមួយយុវជននោះទេ។ អ្នកសម្របសម្រួលក្លឹប SNYC នៅតែអាចនិយាយជាមួយ យុវជន នៅកន្លែងដែលគ្មាននរណាអាចឮបាន ប៉ុន្តែត្រូវមាននរណាម្នាក់នៅក្នុងបន្ទប់នោះ ដែលអាចឃើញពួកគាត់ដែរ។

ប្រសិនបើសមាជិកក្លឹប SNYC ណាម្នាក់ឈប់មកចូលរួម អ្នកសម្របសម្រួលគួរសួរ មិត្តភក្តិរបស់សមាជិកនោះថាតើ សមាជិកនោះមានបញ្ហាអ្វីឬទេ។ ប្រសិនបើអាចទៅរួច

អ្នកសម្របសម្រួលក្លឹប SNYC គួរទៅផ្ទះរបស់យុវជននោះ ដើម្បីដឹងថាហេតុអ្វីយុវជនរូបនោះឈប់មកចូលរួម។

## ត្រូវស្គាល់ពីកម្រិតយល់ដឹងរបស់ខ្លួន

ពន្យល់ថា អ្នកសម្របសម្រួលក្លឹប SNYC គួរស្គាល់អំពីកម្រិតយល់ដឹងរបស់ខ្លួន មានន័យថា អ្នកសម្របសម្រួលក្លឹប SNYC គួរទទួលស្គាល់ស្ថានភាពដែលពួកគាត់មិនអាចដោះស្រាយបាន។ អ្នកសម្របសម្រួលក្លឹប SNYC អាចជួយយុវជនឲ្យរៀនជំនាញដើម្បីធ្វើឲ្យជីវិតពួកគាត់ប្រសើរឡើង ហើយធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ប៉ុន្តែអ្នកសម្របសម្រួលក្លឹប SNYC មិនអាចធ្វើអ្វីៗបានគ្រប់យ៉ាងនោះឡើយ។ ខាងក្រោយនេះគឺជាគន្លឹះដ៏មានប្រយោជន៍មួយចំនួនៈ

- *កុំខំធ្វើជាគ្រូពេទ្យ៖* ប្រសិនបើសមាជិកក្លឹប SNYC ម្នាក់មានជំងឺ អ្នកសម្របសម្រួល ក្លឹប SNYC អាចប្រាប់ឲ្យសមាជិកនោះទៅគ្លីនិក ប៉ុន្តែមិនអាចផ្តល់ថ្នាំព្យាបាល ឬដំបូន្មានវេជ្ជសាស្ត្របានទេ។
- *កុំខំធ្វើជាឪពុកម្តាយរបស់ពួកគាត់៖* ប្រសិនបើសមាជិកក្លឹប SNYC ម្នាក់មិនមានផ្ទះសម្បែងអ្នកសម្របសម្រួលក្លឹប SNYC អាចប្រាប់ឲ្យសមាជិកនោះទៅអង្គការ NGO ប៉ុន្តែមិនអនុញ្ញាតឲ្យសមាជិកនោះចូលមកស្នាក់នៅផ្ទះរបស់អ្នកសម្របសម្រួលនោះឡើយ។
- *កុំខំធ្វើជាមន្ត្រីប៉ូលីស៖* ប្រសិនបើយុវជនម្នាក់ត្រូវរងរបួស ឬកំពុងធ្វើឲ្យរបួសដោយសារឪពុកម្តាយ ឬអ្នកដទៃនោះ សូមទូរសព្ទមកអ្នកគ្រប់គ្រងអង្គការទស្សនៈពិភពលោកនៅថ្ងៃនោះ ហើយបន្ទាប់មក អនុវត្តតាមនីតិវិធីនៅក្នុងផែនការឆ្លើយតបក្នុងឧបករណ៍នារីកឆ្លាត។អ្នកសម្របសម្រួលក្លឹបSNYCមិនគួរទៅជួបគ្រួសារនោះតែឯកឯងនោះទេ។
- *ត្រូវធ្វើជាមនុស្សម្នាក់ដែលមានសីលធម៌វិជ្ជាជីវៈ៖*ត្រូវកសាងទំនាក់ទំនងជាមួយយុវជន ប៉ុន្តែនៅតែរក្សាសីលធម៌វិជ្ជាជីវៈ។ ឧទាហរណ៍អ្នកសម្របសម្រួលក្លឹប SNYCមិនគួរប្រាប់យុវជនអំពីទំនាក់ទំនងស្នេហាផ្ទាល់ខ្លួនដល់យុវជនឡើយ។ ជាការល្អនោះត្រូវចូលរួមជាក្រុមក្នុងសង្គមជាមួយអ្នកចូលរួមក្លឹប SNYC ប៉ុន្តែអ្នកសម្របសម្រួលក្លឹប SNYC មិនគួរចេញក្រៅតែឯកឯងជាមួយសមាជិកក្លឹបSNYCតែម្នាក់នោះទេ។ត្រូវចាំថាអ្នកសម្របសម្រួលក្លឹបSNYCគួរតែជាមិត្តនិងជាគំរូល្អ។
- *ទទួលស្គាល់ពីកម្រិតចំណេះដឹងរបស់អ្នក៖* ជាធម្មតា គ្រូល្អបំផុតនិយាយថា «ខ្ញុំមិនដឹងចម្លើយទេ ប៉ុន្តែខ្ញុំអាចរកចម្លើយនោះបាន»។ ប្រសិនបើអ្នកចូលរួមជាយុវជនសួរសំណួរដែលអ្នកសម្របសម្រួលមិន អាចឆ្លើយបានអ្នកសម្របសម្រួលក្លឹប SNYC គួរតែសម្តែងការស្មោះត្រង់ ហើយពន្យល់ថាខ្លួនមិនដឹងចម្លើយទេ។ អ្នកសម្របសម្រួលនោះ គួរតែស្វែងរកចម្លើយដោយសួរទៅអ្នក

ដែលដឹង ឬរកចម្លើយតាមរយៈអ៊ីនធើណេត។ ធ្វើដូច្នេះ អ្នកសម្របសម្រួលក្លឹប SNYC នឹងអាចជួយអ្នកសម្របសម្រួលជាយុវជនឲ្យទទួលបានព័ត៌មាន ត្រឹមត្រូវ និងបង្ហាញអំពីរបៀបស្រាវជ្រាវទៀតផង។

## សកម្មភាព៖ ការស្វែងយល់អំពីយុវជន

បែងចែកយុវជនជាក្រុមដែលមានសមាជិក៦ទៅ៨នាក់។ ត្រូវចែក «ប័ណ្ណព័ត៌មានលេខ ៥ក ៖ ករណីសិក្សា តារាង១» ឲ្យអ្នកចូលរួម ហើយប្រាប់សមាជិកក្រុមឲ្យអានករណីសិក្សានីមួយៗ ហើយបន្ទាប់មកពិភាក្សាពីអារម្មណ៍របស់ពួកគាត់ដែលកើតមាន ចំពោះករណីនីមួយៗ ។

១០នាទីក្រោយ ត្រូវចែក «ប័ណ្ណព័ត៌មានលេខ ៥ខ ៖ ករណីសិក្សា តារាង២» ហើយពន្យល់ថារឿងរ៉ាវ ទាំងនេះពណ៌នាអំពីជីវិតអាថ៌កំបាំងរបស់យុវជនដែលពួកគាត់ទើបតែបានអាន។

នៅពេលដែលពួកគាត់បានអានរឿងរ៉ាវទាំងនោះហើយ ប្រាប់ឲ្យពួកគាត់ពិភាក្សាសំណួរដូចខាងក្រោម៖

- តើខ្ញុំអាចជួយយុវជនដូចនេះដោយរបៀបណា?
- តើខ្ញុំអាចធ្វើអ្វីបានខ្លះ ដើម្បីឲ្យកាន់តែងាយស្រួល ក្នុងការសហការជាមួយយុវជនបែបនេះ?

### សង្ខេបមេរៀន

- អ្នកសម្របសម្រួលក្លឹប SNYC គួរយល់ថា ក្មេងជំទង់ជួបអារម្មណ៍ខ្លាំងក្លា ហើយថានេះគឺជាដំណាក់កាល ធម្មតានៃការអភិវឌ្ឍន៍។
- អ្នកសម្របសម្រួលក្លឹប SNYC គួរកសាងទំនាក់ទំនងវិជ្ជមានជាមួយអ្នកចូលរួមជាយុវជន ដើម្បីជំរុញការ សិក្សា និងវត្តមាន។
- អ្នកសម្របសម្រួលក្លឹប SNYC គួរស្គាល់ពីកម្រិតយល់ដឹងរបស់ពួកខ្លួនហើយ៖
  - » មិនផ្តល់ដំបូន្មានផ្នែកវិជ្ជសាស្ត្រ
  - » មិនអនុញ្ញាតឲ្យយុវជនស្នាក់នៅជាមួយ
  - » អនុវត្តតាមផែនការឆ្លើយតប ប្រសិនបើយុវជនរាយការណ៍អំពីការរំលោភបំពាន
  - » ជាអ្នកមានសីលធម៌វិជ្ជាជីវៈ
  - » ស្មោះត្រង់ ប្រសិនបើខ្លួនមិនដឹងចម្លើយក្នុងសំណួរណាមួយ

## ប័ណ្ណព័ត៌មានលេខ ៥ក ៖ ករណីសិក្សា សារាង១

យុវជន ក គឺជាសមាជិកម្នាក់របស់យុវជនមួយក្រុម។ ក្មេងប្រុសនេះមានកម្ពស់ខ្ពស់ គឺខ្ពស់ជាងក្មេងដទៃទៀត។ គាត់មានសម្លេងខ្លាំងៗ ហើយជាញឹកញាប់តែងគំរាមកំហែង ដល់យុវជនដទៃ។ គាត់ជាញឹកញាប់តែងនិយាយកាត់សម្តីអ្នកដទៃ ហើយហាក់ដូចជាខឹង សម្បារគ្រប់ពេលវេលា។ ក្មេងបែបនេះ ពិបាកនឹងឲ្យយើងធ្វើការជាមួយណាស់។

នាង ខ គឺជាក្មេងស្រីជំទង់ម្នាក់។ ពេលខ្លះនាងមកចូលរួមក្រុម ប៉ុន្តែពេលខ្លះទៀត នាងចំណាយពេលទៅគូររូប នៅក្នុងសៀវភៅកត់ត្រារបស់នាងទៅវិញ។ នាងហាក់ដូចជា មិនស្តាប់ ហើយអ្នកមានអារម្មណ៍ថា នៅពេលនាងគូររូបនាងមិនមានការគោរពចំពោះអ្នក ឡើយ ។ ពេលខ្លះនាងមិនមកចូលរួម ហើយទង្វើបែបនេះធ្វើឲ្យអ្នកមានអារម្មណ៍ខឹង។

យុវជន ម គឺជាមនុស្សចូលចិត្តកំប្លែងលេង។ គាត់ហាក់ដូចជាមិនសូវយកចិត្តទុកដាក់ ទេ។ គាត់អង្គុយនៅខាងក្រោយក្រុម ហើយធ្វើពុតជាមនុស្ស «អស្ចារ្យ» ហើយមិនចូលរួមក្នុង សកម្មភាពនានាទេ។គាត់និយាយចែចង់ជាមួយក្មេងស្រីទាំងអស់។គាត់ព្យាយាមធ្វើឲ្យយុវជន ដទៃទៀតសើចចំអកឲ្យអ្នក។ សរុបមក គាត់ធ្វើឲ្យ អ្នកមានអារម្មណ៍ភ័យព្រួយ។

## ប័ណ្ណព័ត៌មានលេខ ៥ខ ៖ ករណីសិក្សា សារាង២

យុវជន ក កំពុងលាក់បាំងអំពីការដែលខ្លួនមិនសូវចេះអានអក្សរ។ ជាញឹកញាប់ គ្រួសារ គាត់បានឃាត់គាត់មិនឲ្យទៅសាលារៀន ដើម្បីនៅជួយការងារផ្ទះ។ គាត់ខ្លាចយុវជនដឹងថា ខ្លួនមិនចេះអាន ហើយនឹងនាំគ្នាសើចចំអកឲ្យខ្លួន។ ឪពុកគាត់គឺជាមនុស្សប្រមឹក ហើយវាយ ធ្វើបាបកូននៅពេលដែលគាត់ស្រវឹង។ យុវជន ក បានរៀនសូត្រក្លាយជាមនុស្សចេះស៊ូទ្រាំនៅ ពេលឪពុករបស់គាត់វាយគាត់ ហើយឥឡូវនេះ គាត់ព្យាយាមគំរាមកំហែងអ្នកដទៃ ដើម្បីកុំឲ្យ អ្នកដទៃគំរាមគាត់ទាន់។

នាង ខ កំពុងស្ថិតក្នុងវ័យជំទង់ ហើយតែងជួបប្រទះអារម្មណ៍ប្រែប្រួល។ នៅក្នុង ក្រុមមានក្មេងប្រុសម្នាក់ ដែលនាងចូលចិត្ត ប៉ុន្តែក្មេងប្រុសនោះមិនអើពើនាងទេ។ នៅពេល នាងដឹងថា ក្មេងប្រុសនោះស្រលាញ់មិត្តរបស់ខ្លួន នាង ខ មានអារម្មណ៍ខូចចិត្ត ខ្លាំងណាស់។ នាងមិនអាចនិយាយជាមួយគ្រួសាររបស់នាង ឬមិត្តភក្តិណាម្នាក់របស់នាងអំពីបញ្ហានេះទេ។ នាងបានធ្វើដំណើរទៅមាត់ទន្លេនៅយប់មួយ ហើយគិតចង់លោតទឹកសម្លាប់ខ្លួន។

គ្រួសាររបស់យុវជន ម គឺគ្រួសារក្រីក្រមួយ ហើយបងប្រុសទាំងអស់របស់គាត់ បាន ធ្វើចំណាកស្រុក។ គាត់ព្រួយបារម្ភថា បងប្រុសទាំងនោះកំពុងធ្វើការលើទូកនេសាទថៃ ដោយ សារយុវជន ម មិនធ្លាប់ទទួលបានដំណឹងអ្វីពីបងប្រុសគាត់ឡើយ។ គាត់ចង់បានជំនួនាន របស់អ្នក ប៉ុន្តែគាត់គិតថា គាត់មិនអាចជួយអ្វីបានឡើយ ព្រោះគ្រួសារគាត់ក្រីក្រណាស់ ហើយ គាត់ក៏មិនអាចរារាំងអ្វីបានដែរ។ នេះហើយជាហេតុផលដែលគាត់ព្យាយាមបំផ្លាញអ្វី ដែល អ្នកកំពុងនិយាយ ដោយការនិយាយកំប្លែងលេងទៅវិញ។

# មេរៀនទី៦៖ ជំនាញសម្របសម្រួលៈ កិច្ចសហការ

## វត្ថុបំណង

អ្នកចូលរួមនឹងបានយល់ដឹង ហើយនឹងអនុវត្តជំនាញសម្របសម្រួលដើម្បីធ្វើកិច្ចសហការជាមួយយុវជន។

## រយៈពេល

៣០ នាទី

## សម្ភារ

- ឯកសារថតចម្លង «ប័ណ្ណព័ត៌មានលេខ ៦ក ៖ ជំនាញធ្វើបទបង្ហាញ» សម្រាប់អ្នកចូលរួមនីមួយៗ
- ឯកសារថតចម្លងឧបករណ៍នាវិកឆ្លាតសម្រាប់អ្នកចូលរួមនីមួយៗ

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ ២-៣ រូប មកពីក្លឹប SNYC នីមួយៗ

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្តុះបណ្តាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP ។

## សេចក្តីណែនាំ

លើកទឹកចិត្តអ្នកចូលរួមឲ្យសួរសំណួរ នៅពេលដែលអ្នកបង្ហាញព័ត៌មានដូចខាងក្រោម។

### យុវជនចាំបាច់ត្រូវមានសកម្មភាព

ពន្យល់ថា យុវជនមានថាមពលផ្នែករាង្គកាយច្រើនណាស់។ វាពិបាកណាស់សម្រាប់យុវជនដែលអង្គុយស្ងៀមក្នុងរយៈពេលយូរ។ ខួរក្បាលរបស់កុមារម្នាក់រីកចម្រើនលឿនខ្លាំងរហូតដល់អាយុ១៨ឆ្នាំ ហើយការសិក្សាស្រាវជ្រាវបានបង្ហាញថា កុមារចាំបាច់ត្រូវមានសកម្មភាពជានិច្ច ដើម្បីបណ្តុះបញ្ញា។

ចូរសួរថា៖ តើមាននរណាអាចចាំបានថា ធ្លាប់អង្គុយក្នុងបន្ទប់រៀនស្តាប់គ្រូនិយាយ ហើយនិយាយទៀត អស់រយៈពេលច្រើនម៉ោងឬទេ? ដូចជា «តើអ្នកបានសម្លឹងតាមបង្អួចទៅខាងក្រៅ ដើម្បីរង់ចាំរហូតដល់ចប់ម៉ោងសិក្សា ឬទេ?» អ្វីដែលសំខាន់នោះ គឺអ្នកចូលរួមជាយុវជន មិនមានការធុញទ្រាន់នៅក្នុងក្លឹប SNYC ឬមិនមែនគ្រាន់តែមកអង្គុយរង់ចាំឲ្យចប់ម៉ោងសិក្សានោះទេ។

ឧបករណ៍នារីកវៃឆ្លាតនេះ ត្រូវបានបង្កើតឡើងដើម្បីធ្វើឲ្យយុវជនមានភាពសកម្ម។ រាល់មេរៀនចាប់ផ្តើមដោយល្បែង ហើយមានបញ្ចូលសកម្មភាពអ្វីមួយ ដែលតម្រូវឲ្យយុវជនលេងកំសាន្ត ឬធ្វើការនៅក្នុងក្រុម។ ឧបករណ៍នារីកឆ្លាតនេះ ក៏មានបញ្ចូលផ្នែកដែលមានព័ត៌មានសម្រាប់ឲ្យអ្នកសម្របសម្រួលក្លឹប SNYC ពន្យល់ទៅកាន់យុវជនផងដែរ។ នៅពេលពន្យល់អំពីព័ត៌មានទាំងនេះ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរនិយាយយូរពេកទេ។ ប្រសិនបើក្លឹប SNYC ក្លាយទៅជាកន្លែងដ៏គួរឲ្យធុញទ្រាន់នោះ អ្នកចូលរួមនឹងឈប់មករៀនមិនខាន។

## យុវជននឹងយកចិត្តទុកដាក់ស្តាប់ ប្រសិនបើអ្នកនិយាយដោយភាពរស់រវើក

ពន្យល់ថា នៅពេលដែលអ្នកសម្របសម្រួលក្លឹប SNYC និយាយទៅកាន់អ្នកចូលរួមជាយុវជន ពួកគាត់គួរព្យាយាមប្រើប្រាស់ភាពរស់រវើករបស់ខ្លួនទៅក្នុងការនិយាយ។ អ្នកសម្របសម្រួលក្លឹប SNYC គួរព្យាយាមទាក់ទាញការចាប់អារម្មណ៍។ វិធីមួយចំនួនដែលអ្នកសម្របសម្រួលអាចធ្វើបានរួមមាន ៖

- ដើរជុំវិញបន្ទប់នៅពេលនិយាយ
- ប្រើកាយវិការនៅពេលនិយាយ
- សម្លឹងមើលភ្នែករបស់អ្នកចូលរួម
- និយាយកំប្លែងលេងសើច (ប៉ុន្តែមិនត្រូវសើចចំអកដល់អ្នកចូលរួមទេ)
- ធ្វើអារម្មណ៍រីករាយ

## សកម្មភាព៖ ជំនាញធ្វើបទបង្ហាញ

ប្រាប់អ្នកចូលរួមឲ្យរកដៃគូម្នាក់។ ចែកឯកសារចម្លងនៃ «ប័ណ្ណព័ត៌មាន លេខ៦ក៖ ជំនាញធ្វើបទបង្ហាញ» ឲ្យអ្នកចូលរួមនីមួយៗ ហើយប្រាប់ឲ្យពួកគាត់អានឯកសារនោះ។ បន្ទាប់មក ប្រាប់ពួកគាត់ឲ្យយកឧបករណ៍នារីកវៃឆ្លាតរបស់ពួកខ្លួនចេញមក ហើយមើលទៅមេរៀនទី១៣ ដែលមានចំណងជើងថា «ការឡើងនិយាយ (ជំនាញទំនាក់ទំនង)»។ ប្រាប់អ្នកចូលរួមឲ្យប្រើរយៈពេល១នាទីអានសេចក្តីណែនាំ។ បន្ទាប់មកប្រាប់ពួកគាត់ឲ្យព្យាយាមអានសេចក្តីណែនាំនេះឲ្យដៃគូរបស់ខ្លួនស្តាប់ ដោយចាំថាត្រូវប្រើ «ជំនាញធ្វើបទបង្ហាញ»។ នៅពេលពួកគាត់បានធ្វើរួចហើយប្រាប់ពួកគាត់ឲ្យមើលបញ្ជីហើយសហការជាមួយដៃគូរបស់ខ្លួនដើម្បីសម្រេចថា តើជំនាញមួយណាដែលពួកគាត់បានប្រើ ហើយមួយណាដែលមានលក្ខណៈពិបាកជាងគេ។ ដៃគូគួរតែផ្តល់ការគាំទ្រមិនមែនផ្តល់ការវិនិច្ឆ័យទេ។ បន្ទាប់មកបាប្រ់អ្នកចូលរួមឲ្យប្តូរ គូនាទី ហើយអនុវត្តសកម្មភាពនេះម្តងទៀត។

ពេលដៃគូទាំងពីរបានប្តូរវេនម្តងម្នាក់រួចហើយ ប្រាប់ពួកគាត់ឲ្យអនុវត្តសកម្មភាពនោះទាំងស្រុងម្តងទៀត។

ក្រោយពេលសមាជិកគ្រប់គ្នាក្នុងក្រុម បានអនុវត្តយ៉ាងតិចម្នាក់ពីរដងរួចហើយនោះ ចូរប្រាប់អ្នកចូលរួមឲ្យមកផ្តុំគ្នាជាក្រុមមួយ ហើយសួរថា ៖

- តើអ្នកមានអារម្មណ៍ដូចម្តេច ក្នុងការអនុវត្តសកម្មភាពនេះ?
- តើមានជំនាញមួយណាខ្លះដែលងាយស្រួលប្រើ?
- តើមានជំនាញមួយណាដែលពិបាក?
- ហេតុអ្វីបានជាជំនាញនោះពិបាក?
- តើអ្នកមានអារម្មណ៍ថា អ្នកមានការរីកចម្រើនឬទេ នៅពេលអ្នកអនុវត្តកាន់តែច្រើន?
- តើមានអ្នកណា ដែលមានល្បិចងាយៗ ហើយចង់ចែករំលែកដល់ក្រុម ឬទេ?

## សេចក្តីណែនាំ៖ ការឡើងនិយាយទស្សនៈការផ្សារភ្ជាប់នឹងជីវិតយុវជន អំពើហិង្សា ឬការចំអក

### យុវជនចាំបាច់ត្រូវហ៊ានឡើងនិយាយ

អានផ្នែកខាងក្រោមនេះឲ្យអ្នកចូលរួមស្តាប់ ។ លើកទឹកចិតឲ្យពួកគាត់សួរសំណួរ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) របស់អង្គការសហប្រជាជាតិបានចែងថា យុវជនគួរមានសិទ្ធិសម្តែងមតិ របស់ខ្លួនទៅលើបញ្ហាដែលប៉ះពាល់ដល់ពួកគាត់។ តាមប្រពៃណីយុវជននៅអាស៊ីត្រូវគេរំពឹងថា ត្រូវមានសភាពស្ងៀមស្ងាត់ ធ្វើតាមការណែនាំមនុស្សពេញវ័យ មិនឲ្យសួរដេញដោល ឬសួរនាំអំពីសិទ្ធិអំណាច។ ប៉ុន្តែបច្ចុប្បន្ននេះ យុវជនចាំបាច់ត្រូវរៀនអំពីរបៀបឡើងសម្តែងមតិចេញមក ដើម្បីការពារខ្លួនឲ្យរួចផុតពីកលល្បិចរបស់អ្នកជួញដូរមនុស្ស។ ជាការសំខាន់ អ្នកសម្របសម្រួលក្លឹប SNYC ត្រូវលើកទឹកចិត្តឲ្យយុវជនហ៊ានឡើងនិយាយ និងចែករំលែកទស្សនៈរបស់ពួកខ្លួន។

### យុវជនអាចបង្កើតទស្សនៈផ្ទាល់ខ្លួន

ពន្យល់ថាឧបករណ៍នារីកវៃឆ្លាតនេះព្យាយាមឲ្យយុវជនផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួនដើម្បីឲ្យពួកគាត់ពន្យារការធ្វើចំណាកស្រុក និងធ្វើចំណាកស្រុកប្រកដដោយសុវត្ថិភាពជាងមុន នៅពេលដែលពួកគាត់ធ្វើចំណាកស្រុក។ ការសិក្សាបានបង្ហាញថា មនុស្សទំនងជាផ្លាស់ប្តូរអាកប្បកិរិយា នៅពេលពួកគាត់មានអារម្មណ៍ថា ខ្លួនធ្វើការសម្រេចចិត្តដោយឯករាជ្យ។

អ្នកសម្របសម្រួលក្លឹប SNYC គួរព្យាយាមផ្តល់ឱកាសឲ្យយុវជនឲ្យបង្កើតទស្សនៈផ្ទាល់ខ្លួន។ ឧបករណ៍នារីកវៃឆ្លាតនេះ នឹងផ្តល់ព័ត៌មានរបស់អ្នកសម្របសម្រួល។ អ្នកសម្របសម្រួលក្លឹប SNYC គួរព្យាយាមប្រើប្រាស់ល្បែង និងសកម្មភាព ដើម្បីអាចឲ្យយុវជនប្រើប្រាស់ព័ត៌មាននេះក្នុងការធ្វើការសម្រេចចិត្តទៅលើបញ្ហាទាំងនេះ។

## ការសិក្សារៀនសូត្រ គួរផ្សារភ្ជាប់ទៅនឹងជីវិតរបស់យុវជន

ចូរពន្យល់ថា មនុស្សរៀនឆាប់ចាប់បានបំផុត គឺនៅពេលប្រធានបទដែលគេកំពុងសិក្សានោះមានការពាក់ព័ន្ធនឹងជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់។ អ្នកចូលរួមក្លឹបSNYCចាំបាច់ត្រូវដឹងថាការជួញដូរគឺជាគ្រោះថ្នាក់ពិតប្រាកដមួយ ហើយថាការជួញដូរអាចកើតឡើងលើយុវជន ដូចជាពួកគាត់នេះ។

អ្នកសម្របសម្រួលក្លឹប SNYC ល្អមួយរូប បន្តព្យាយាមផ្សារភ្ជាប់មេរៀនទៅនឹងស្ថានភាពពិតជាក់ស្តែងនៅក្នុងសហគមន៍ ឬនៅក្នុងជីវិតរបស់យុវជន។ នៅពេលដែលអ្នកសម្របសម្រួលក្លឹប SNYC បង្រៀនពួកគាត់ គួរតែពិចារណាជានិច្ចថា តើត្រូវផ្សារភ្ជាប់មេរៀន ទៅនឹងជីវិតពិតជាក់ស្តែងដោយវិធីណា។ អ្នកសម្របសម្រួលក្លឹប SNYC គួររំឭកអ្នកចូលរួមជាយុវជនថាឧបករណ៍នារីកឆ្លាតនេះប្រើប្រាស់លើករណីសិក្សាដែលបានមកពីរឿងរ៉ាវពិតរបស់យុវជនដែល រស់នៅក្នុងសហគមន៍ ដូចជាសហគមន៍របស់ពួកគាត់ដែរ។

### អំពើហឹង្សា ឬការចំអក

ចូរប្រាប់អ្នកចូលរួមឲ្យបិទភ្នែក ហើយគិតត្រឡប់ទៅគ្រាមួយនៅសាលារៀន នៅពេលគ្រូបានវាយដំ ឬចំអកឲ្យខ្លួន។ ចូរប្រាប់ឲ្យពួកគាត់ចងចាំនូវអ្វីដែលពួកគាត់បានគិត ហើយមានអារម្មណ៍ដូចម្តេចនៅពេលនោះ។ សួរថា «តើអ្នកកំពុងគិតអំពីប្រធានបទដែលគ្រូកំពុងពិភាក្សាឬ?តើអ្នកកំពុងមានអារម្មណ៍មិនសប្បាយចិត្ត និងមានកំហឹង ដោយសារវិធីដែលគ្រូបានធ្វើឲ្យអ្នកឈឺចាប់នោះ ឬទេ?

ពន្យល់ថា មនុស្សពេញវ័យមួយចំនួនជឿថា ការវាយដំការមើលងាយ ឬការសើចចំអកដាក់យុវជន នឹងបង្ខំឲ្យយុវជនរៀនសូត្រ។ រឿងនេះមិនពិតឡើយ។ ការសិក្សាបង្ហាញថាការរំលោភបំពានរាងកាយ ឬអារម្មណ៍បែបនេះ មានផលប៉ះពាល់បញ្ច្រាសគ្នាទៅវិញទេ។ វាធ្វើឲ្យរាំងស្ទះដល់អារម្មណ៍សិក្សារបស់យុវជន ។ ចូរពន្យល់ថា អ្នកសម្របសម្រួលក្លឹប SNYC ល្អមួយរូបគឺ ៖

- មិនវាយដំ ឬធ្វើឲ្យរបួសរាង្គកាយយុវជន ទោះក្នុងលក្ខណៈណាក៏ដោយ
- មិនសើចចំអកឲ្យយុវជន
- មិនប្រមាថយុវជនទោះក្នុងលក្ខណៈណាក៏ដោយ(ឧទាហរណ៍អ្នកសម្របសម្រួលមិនគួរប្រាប់ឲ្យយុវជន ឈរបែរមុខទៅរកជញ្ជាំង ឬឲ្យអង្គុយនៅឆ្ងាយពីក្រុមដើម្បីជាការដាក់ពិន័យនោះទេ។
- កុំធ្វើការប្រៀបធៀបអ្នកសម្របសម្រួលជាសាធារណៈ (ឧទាហរណ៍ អ្នកសម្របសម្រួលមិនគួរនិយាយថាអ្នកចូលរួមម្នាក់«ល្អណាស់» ហើយអ្នកចូលរួមម្នាក់ទៀត «អាក្រក់ណាស់» នោះទេ។ ប្រសិនបើអ្នកធ្វើអញ្ចឹង អ្នកចូលរួមដែលអ្នកថាអាក្រក់នឹងអាចនឹងឈប់មកកាន់ក្លឹប SNYC)។

លើសពីនេះទៀត អង្គការទស្សនៈពិភពលោកមានគោលនយោបាយការពារកុមារ

ដ៏រឹងមាំ ដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធ ក នៅក្នុងឧបករណ៍នេះ ដែលគោលនយោបាយនេះហាមឃាត់មនុស្សពេញវ័យមិនឲ្យវាយដំ ឬ ធ្វើឲ្យយុវជនរបួស ទោះជាក្នុងលក្ខណៈណាក៏ដោយ។

### សង្ខេបមេរៀន

អ្នកសម្របសម្រួលក្លឹប SNYC គួរ ៖

- លើកទឹកចិត្តយុវជនឲ្យមានភាពសកម្មនៅក្នុងក្លឹប SNYC
- និយាយដោយភាពរស់រវើក
- លើកទឹកចិត្តយុវជនឲ្យហ៊ានឡើងនិយាយ
- លើកទឹកចិត្តយុវជនឲ្យសម្តែងទស្សនៈពិត
- ផ្សារភ្ជាប់មេរៀនទៅនឹងជីវិតរបស់យុវជន
- ប្រើប្រាស់វិន័យវិជ្ជមាន ហើយមិនត្រូវវាយដំ ធ្វើឲ្យរបួស ឬប្រមាថយុវជនឡើយ

## ប័ណ្ណព័ត៌មានលេខ ៦ក ៖ ជំនាញធ្វើបទបង្ហាញ

ដើរជុំវិញបន្ទប់ នៅពេលអ្នកនិយាយ

សួរសំណួរ

ប្រើដៃធ្វើកាយវិការ ដើម្បីបញ្ជាក់ន័យឲ្យកាន់តែច្បាស់

ផ្សារភ្ជាប់មេរៀនទៅនឹងជីវិតរបស់អ្នកចូលរួម

សម្លឹងមើលភ្នែកអ្នកចូលរួម

កំប្លែងលេង (ប៉ុន្តែកុំសើចចំអកដល់អ្នកចូលរួម)

ធ្វើអារម្មណ៍រីករាយ

# មេរៀនទី៧ ៖ របៀបសម្របសម្រួលការពិភាក្សា

## វត្ថុបំណង

អ្នកចូលរួមនឹងបានយល់ដឹងអំពីរបៀបសម្របសម្រួលការពិភាក្សា។

## រយៈពេល

៦០ នាទី

## សម្ភារ

- ឯកសារថតចម្លងនៃ
  - » ប័ណ្ណព័ត៌មានលេខ ៧ក ៖ ការដើរតួក្នុងការពិភាក្សា ត្រូវកាត់ជាប័ណ្ណដាច់ដោយឡែកពីគ្នា
  - » ប័ណ្ណព័ត៌មានលេខ ៧ខ ៖ សម្របសម្រួលការពិភាក្សាសម្រាប់អ្នកចូលរួមនីមួយៗ

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ ២-៣ រូប មកពីក្លឹប SNYC នីមួយៗ

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្តុះបណ្តាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP ។

## សេចក្តីណែនាំ

ចូរពន្យល់ថា សៀវភៅណែនាំនេះលើកទឹកចិត្តយុវជនឲ្យពិភាក្សាបញ្ហាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគាត់។ សកម្មភាពពិភាក្សាជាក្រុម ត្រូវបានប្រើប្រាស់នៅក្នុងឧបករណ៍នាវិកវៃឆ្លាតទាំងមូល ។

ចូរពន្យល់ថា មេរៀននេះ គឺស្តីអំពីបច្ចេកទេស នៅក្នុងការជួយសម្របសម្រួលដល់ការពិភាក្សា។ អានចំណុចខាងក្រោមនេះ ឲ្យអ្នកចូលរួមស្តាប់។

## របៀបសម្របសម្រួលការពិភាក្សា

- **បញ្ចូលអ្នកចូលរួមដែលស្ងាត់ស្ងៀមក្នុងក្រុម៖** សង្កេតមើលក្រុម។ ប្រសិនបើនរណាម្នាក់មិននិយាយទេ សូមសួរពួកគាត់ដោយទន់ភ្លន់ថា តើពួកគាត់មានទស្សនៈយ៉ាងណាដែរ ចំពោះប្រធានបទនេះ។ សូមកុំបង្ខំអ្នកចូលរួមឲ្យនិយាយ ប៉ុន្តែអញ្ជើញពួកគាត់ ប្រសិនបើពួកគាត់ស្ម័គ្រចិត្ត។
- **ដាក់កំណត់លើអ្នកដែលនិយាយច្រើន៖** ប្រសិនបើអ្នកចូលរួមម្នាក់និយាយតឯងនោះសូមស្នើសុំដោយគួរសមឲ្យគាត់ផ្តល់ឱកាសដល់អ្នកដទៃផង។ឧទាហរណ៍រង់ចាំដល់ពេលអ្នកចូលរួមនោះនិយាយចប់ប្រយោគរបស់គាត់ ហើយនិយាយថា **«អរគុណសម្រាប់ការបញ្ចេញមតិ។ សូមទោសដែលបញ្ឈប់អ្នកត្រឹមនេះ ប៉ុន្តែយើងមានពេលវេលាកំណត់។ តើខ្ញុំអាចសួរថាតើមាននរណាផ្សេងទៀតមានយោបល់លើបញ្ហានេះទេ?»**
- **និយាយឡើងវិញ៖** អ្នកអាចជួយឲ្យការពិភាក្សាមានដំណើរការទៅបានដោយនិយាយឡើងវិញនូវអ្វី ដែលនរណាម្នាក់ទើបបាននិយាយ ហើយសួរថាតើអ្នក ដទៃទៀតយល់ស្រប ឬមិនយល់ស្រប។ **ឧទាហរណ៍ «នាង ទើបនិយាយថា______________ ។ តើអ្នកយល់ស្របដែរឬទេ?**
- **ស្តាប់៖** ប្រសិនបើអ្នកពិតជាស្តាប់អ្វី ដែលយុវជននិយាយ ពួកគាត់នឹងកាន់តែចង់និយាយថែមទៀត។ អ្នកក៏អាចគិតនូវសំណួរពាក់ព័ន្ធនានា ដែលអាចជួយដល់ការពិភាក្សា។
- សួរសំណួរច្រើន៖សំណួរទាំងនេះ គួរជាសំណួរអំពីអ្វីដែលយុវជនដទៃទៀតគិត ឬជឿ មិនមែនគ្រាន់តែជាសំណួរដែលសាកល្បងចំណេះដឹងអំពីការពិតនោះទេ។ឧទាហរណ៍នៃសំណួរអំពីអ្វីដែលយុវជនគិត ឬជឿ រួមមាន៖
    - « តើអ្នកគិតថាជាមូលហេតុអ្វីខ្លះដែលធ្វើឲ្យយុវជនចាកចេញពីសាលារៀន?
    - « តើអ្នកគិតថា អ្នកអាចប្រើប្រាស់បញ្ជីត្រួតពិនិត្យទាំងនេះក្នុងជិវិតផ្ទាល់ខ្លួនអ្នកដែរឬទេ? ហេតុអ្វីអាចប្រើប្រាស់បាន ឬ ហេតុអ្វីមិនអាច?
    សំណួរអំពីចំណេះដឹងគឺ៖
    - « ប្រាប់ឈ្មោះប្រទេសមួយដែលជាគោលដៅពេញនិយមសម្រាប់ការជួញដូរមនុស្ស
    - « នៅក្នុងឧបករណ៍នារីកឆ្លាតអ្នកតម្រង់ទិសឆ្លាតវៃ មានសំណួរជាច្រើនអំពីទស្សនៈនិងគំនិត។

## ឆ្លើយតបទៅនឹងមតិពិបាកៗ

ចូរពន្យល់ថា ពេលខ្លះអ្នកចូលរួមនឹងផ្តល់ទស្សនៈដែលមានលក្ខណៈផ្ទុយគ្នាទៅនឹងគុណតម្លៃរបស់អង្គការទស្សនៈពិភពលោក ឬគោលបំណងនៃឧបករណ៍នារីកឆ្លាតនេះ។ ឧទាហរណ៍

«សាលារៀនគឺគ្មានប្រយោជន៍។ រកការងារពិតប្រាកដធ្វើ នៅតាមរោងចក្រក្នុងវ័យ១៨ឆ្នាំគឺប្រសើរជាង»។

ក្នុងនាមជាអ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់ត្រូវឆ្លើយតបនឹងទស្សនៈនេះ។ ជំហានទី១ ៖

ត្រូវសួរថាតើ មានអ្នកណាផ្សេងនៅក្នុងក្រុម មិនយល់ស្រប ឬទេ? ជំហានបន្ទាប់ គឺសួរសំណួរដែលលើកទឹកចិត្តឲ្យអ្នកចូលរួម នោះពិចារណាឡើងវិញ ។ ឧទាហរណ៍ ៖

«ដើម្បីទទួលបានការងារល្អៗនៅក្នុងរោងចក្រ តើគេត្រូវការជំនាញប្រភេទណា?»

«តើមនុស្សដែលមានកម្រិតអប់រំខ្ពស់ ទទួលបានប្រាក់បៀវត្សរ៍ច្រើន ឬទេ?

បន្ទាប់មក អ្នកសម្របសម្រួលក្លឹប SNYC អាចប្រាប់អំពីគោលជំហរនៃអង្គការទស្សនៈពិភពលោក និង ហេតុផលនៅពីក្រោមគោលជំហរនេះ ដោយការគួរសម។ ឧទាហរណ៍ ៖

«យើងគិតថាសាសារៀនគឺសំខាន់។សាលារៀនអាចឲ្យអ្នកកសាងជំនាញកសាងមិត្តភាព និងធ្វើឲ្យជីវិត អ្នកប្រសើរឡើង។ សាសារៀនបើកទ្វារដើម្បីផ្ដល់ឱកាសការងារនាពេលអនាគត ពីព្រោះការងារមួយភាគធំ ទាមទារនូវការអប់រំ។ ជាធម្មតា មានន័យថាអ្នកអាចទទួលបានការងារដែលផ្ដល់ប្រាក់កម្រៃកាន់តែល្អ នៅពេលអ្នកមានអាយុកាន់តែច្រើន។ សាលារៀនក៏អាចធ្វើឲ្យអ្នកចេះរបៀបអាន និងយល់អំពីកិច្ចសន្យា។ លើសនេះទៀត វាខុសនឹងច្បាប់ប្រទេសយើង បើយុវជនអាយុ១៨ឆ្នាំធ្វើការជាបុគ្គលិកពេញម៉ោងនៅក្នុងរោងចក្រ »។

## សកម្មភាព ៖ សម្របសម្រួលការពិភាក្សា

បែងចែកអ្នកចូលរួមជាក្រុមៗដែលមួយក្រុមមានសមាជិក៨នាក់។ ឲ្យអ្នកចូលរួមនីមួយៗនូវប័ណ្ណយកមកពី «ប័ណ្ណព័ត៌មានលេខ ៖ ៧ក ការដើរតួក្នុងការពិភាក្សា»។ បន្ទាប់មកចែកឯកសារចម្លងនៃ «ប័ណ្ណព័ត៌មានលេខ ៧ខ ៖ សម្របសម្រួលការពិភាក្សា» ឲ្យក្រុមនីមួយៗ។ ចូរពន្យល់ថា អ្នកនឹងដើរតួនៅក្នុងការពិភាក្សា ហើយអ្នកចូលរួមនីមួយៗគួរសម្ដែងដូចដែលបានណែនាំនៅលើប័ណ្ណដែលខ្លួនបានទទួល។ ចូរពន្យល់ថា អ្នកខ្លះអាចត្រូវបានណែនាំឲ្យសម្ដែងរបៀបឈ្លើយបន្តិច ហើយគ្រប់គ្នាត្រូវតែចាំថា ពួកគាត់គ្រាន់តែសំដែងប៉ុណ្ណោះ។ អ្នកដែលទទួលបានប័ណ្ណដើរតួជាអ្នកសម្របសម្រួល គួរព្យាយាមប្រើបច្ចេកទេសដែលមាននៅក្នុង «ប័ណ្ណព័ត៌មានលេខ ៧ខ៖ សម្របសម្រួលការពិភាក្សា»។

អ្នកសម្របសម្រួល គួរជ្រើសរើសប្រធានបទមួយនៃប្រធានបទដូចខាងក្រោមនេះដើម្បីពិភាក្សា៖

- ភាពយន្តពេញនិយម
- បទភ្លេងពេញនិយម
- អាហារបរទេស
- អ្នកកីឡាល្បីល្បាញ

ចូរពន្យល់ថា គំនិតនេះមានគោលដៅពិភាក្សាប្រធានបទដែលមិនទាក់ទងនឹងការជួញដូរ ដើម្បីឲ្យអ្នកចូលរួមអាចផ្ដោតលើជំនាញសម្របសម្រួល ។

ចូរពន្យល់ថា ក្រុមអ្នកចូលរួមគួរពិភាក្សាប្រធានបទមួយរយៈពេលប្រហែល៥នាទី។ នៅពេលពួកគាត់បញ្ចប់សមាជិកទាំងអស់ត្រូវដាក់ប័ណ្ណចូលទៅក្នុងកាបូបមួយច្របល់ចូលគ្នា

ហើយជ្រើសរើសប័ណ្ណថ្មី។ (ប្រសិនបើអ្នកណាម្នាក់ទទួលបានប័ណ្ណជាអ្នកសម្របសម្រួលពីរដង គាត់គួរដាក់ប័ណ្ណនោះចូលទៅក្នុងកាបូបវិញ ហើយយកប័ណ្ណមួយផ្សេងទៀត)។

ក្រុមអ្នកចូលរួមគួរធ្វើបែបនេះឡើងវិញ៣ ឬ៤ដង ដើម្បីអាចឲ្យអ្នកចូលរួមមានឱកាសដើរតួខុសៗគ្នា ។

នៅពេលពួកគាត់បញ្ចប់ ចូរប្រាប់អ្នកចូលរួមឲ្យមកផ្តុំគ្នាជាក្រុមតែមួយ ហើយសួរពួកគាត់ថា ៖

- តើអ្នកមានអារម្មណ៍ដូចម្តេច ក្នុងការអនុវត្តសកម្មភាពនេះ?
- តើមានជំនាញមួយណាខ្លះដែលងាយស្រួលប្រើ?
- តើមានជំនាញមួយណាដែលពិបាក?
- ហេតុអ្វីបានជាជំនាញនោះពិបាក?
- តើមានអ្នកណា ដែលមានល្បិចងាយៗ ហើយចង់ចែករំលែកដល់ក្រុម ឬទេ?

### សង្ខេបមេរៀន

យុទ្ធសាស្ត្រដើម្បីឲ្យមានការសម្របសម្រួលល្អ ៖

- បញ្ចូលអ្នកចូលរួមដែលស្ងាត់ស្ងៀម
- កំណត់ពេលវេលាសម្រាប់អ្នកនិយាយច្រើន
- និយាយឡើងវិញនូវអ្វីដែលអ្នកចូលរួមបាននិយាយ
- ស្តាប់
- សួរសំណួរច្រើនអំពីទស្សនៈរបស់យុវជន
- បង្ហាញអំពីគោលជំហររបស់អង្គការទស្សនៈពិភពលោក នៅពេលអ្នកចូលរួមផ្តល់ទស្សនៈដែលផ្ទុយទៅ នឹងគុណតម្លៃរបស់អង្គការទស្សនៈពិភពលោក

## ប័ណ្ណព័ត៌មានលេខ ៧ក ៖ ដើរតួពិភាក្សា

(សូមកត់សម្គាល់ថា ប័ណ្ណខ្លះត្រូវបានបញ្ចូលពីរដង)

អ្នកគឺជាអ្នកសម្របសម្រួល

អ្នកនិយាយច្រើនពេក ដែលគ្របដណ្តប់លើការពិភាក្សា រហូតដល់អ្នកសម្របសម្រួលនិយាយប្រាប់ដោយពាក្យគួរសមឲ្យអ្នកឈប់។ បន្ទាប់មក ក៏ឈប់និយាយ។ អនុវត្តបែបនេះតែម្តងប៉ុណ្ណោះ។

អ្នកមានការអៀនខ្មាស់។ អ្នកមិននិយាយទេ ប្រសិនបើ ពុំមានការស្នើសុំឲ្យនិយាយ។

អ្នកមានការអៀនខ្មាស់។ អ្នកមិននិយាយទេ ប្រសិនបើ ពុំមានការស្នើសុំឲ្យនិយាយ។

អ្នកនិយាយមិនឈប់ជាមួយអ្នកនៅក្បែរខ្លួន។

អ្នកធ្វើបទបង្ហាញស្តីពី បទអន្តរាគមន៍ទាំង៤ របស់ក្រុមតស៊ូមតិការពារកុមារនៅតាមភូមិ (១-អប់រំផ្សព្វផ្សាយ ២-រាយការណ៍បញ្ជូនឆ្លើយតប ៣-គាំទ្រគ្រួសារងាយរងគ្រោះ ៤-ចែករំលែកបំណិនជីវិតជាមួយក្លឹបយុវជននារីកវៃឆ្លាតតាមភូមិ ) អនុវត្តបែបនេះតែម្តងប៉ុណ្ណោះ។

អ្នកចូលរួមដោយធម្មតាក្នុងការពិភាក្សា។

អ្នកចូលរួមដោយធម្មតាក្នុងការពិភាក្សា។

## ប័ណ្ណព័ត៌មានលេខ ៧ ខ ៖ សម្របសម្រួលការពិភាក្សា

**របៀបសម្របសម្រួលការពិភាក្សា**

- **បញ្ចូលអ្នកចូលរួមដែលស្ងាត់ស្ងៀមក្នុងក្រុម៖** សង្កេតមើលក្រុម។ ប្រសិនបើនរណាម្នាក់មិននិយាយទេ សូមសួរពួកគាត់ដោយទន់ភ្លន់ថា តើពួកគាត់មានទស្សនៈយ៉ាងណាដែរចំពោះប្រធានបទនេះ។ សូមកុំបង្ខំអ្នកចូលរួមឲ្យនិយាយ ប៉ុន្តែអញ្ជើញពួកគាត់ ប្រសិន

បើពួកគាត់ស្ម័គ្រចិត្ត។

- ដាក់កំណត់លើអ្នកដែលនិយាយច្រើន៖ ប្រសិនបើអ្នកចូលរួមម្នាក់និយាយតែងនោះ សូមស្នើសុំដោយគួរសមឲ្យគាត់ផ្តល់ឱកាសដល់អ្នកដទៃផង។ ឧទាហរណ៍ រងចាំដល់ពេលអ្នកចូលរួមនោះនិយាយចប់ប្រយោគរបស់គាត់ ហើយនិយាយថា«អរគុណសម្រាប់ការបញ្ចេញមតិ។ សូមទោសដែលបញ្ឈប់អ្នកត្រឹមនេះ ប៉ុន្តែយើងមានពេលវេលាកំណត់។ តើខ្ញុំអាចសួរថាតើមាននរណាផ្សេងទៀតមានយោបល់លើបញ្ហានេះទេ?»
- **និយាយឡើងវិញ៖** អ្នកអាចជួយឲ្យការពិភាក្សាមានដំណើរការទៅបាន ដោយនិយាយឡើងវិញនូវអ្វីដែលនរណាម្នាក់ទើបបាននិយាយ ហើយសួរថាតើអ្នកដទៃទៀយល់ស្របឬមិនយល់ស្រប។ ឧទាហរណ៍ **« នាងទើបនិយាយថា ______________ ។ តើអ្នកយល់ស្របដែរឬទេ?**
- *ស្តាប់៖* ប្រសិនបើអ្នកពិតជាស្តាប់អ្វី ដែលយុវជននិយាយ ពួកគាត់នឹងកាន់តែចង់និយាយថែមទៀត។ អ្នកក៏អាចគិតនូវសំណួរពាក់ព័ន្ធនានា ដែលអាចជួយដល់ការពិភាក្សា។
- សួរសំណួរច្រើន៖សំណួរទាំងនេះ គួរជាសំណួរអំពីអ្វីដែលយុវជនដទៃទៀតគិត ឬជឿ មិនមែនគ្រាន់តែជា សំណួរដែលសាកល្បងចំណេះដឹងអំពីការពិតនោះទេ។ ឧទាហរណ៍នៃសំណួរអំពីអ្វីដែលយុវជនគិត ឬជឿរួមមាន៖
  - ➢ «តើអ្នកគិតថាជាមូលហេតុអ្វីខ្លះដែលធ្វើឲ្យយុវជនចាកចេញពីសាលារៀន?
  - ➢ «តើអ្នកគិតថា អ្នកអាចប្រើប្រាស់បញ្ជីត្រួតពិនិត្យទាំងនេះក្នុងជីវិតផ្ទាល់ខ្លួនអ្នកដែរឬទេ? ហេតុអ្វីអាចប្រើប្រាស់បាន ឬ ហេតុអ្វីមិនអាច?

  សំណួរអំពីចំណេះដឹងគឺ៖
  - ➢ «ប្រាប់ឈ្មោះប្រទេសមួយដែលជាគោលដៅពេញនិយមសម្រាប់ការជួញដូរ»

# មេរៀនទី៨ ៖ របៀបបង្ហាញប្រធានបទទាក់ទងនឹងផ្លូវភេទ ឬ បញ្ហារំខាន

## វត្ថុបំណង

អ្នកចូលរួមនឹងយល់ដឹងអំពីរបៀបបង្ហាញប្រធានបទទាក់ទងនឹងផ្លូវភេទ ឬ ដែលធ្វើឲ្យខកចិត្ត។

## រយៈពេល

៦០ នាទី

## សម្ភារ

- ឧបករណ៍នាវិកវៃឆ្លាតសម្រាប់អ្នកចូលរួមនីមួយៗ

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ ២-៣ រូប មកពីក្លឹប SNYC នីមួយៗ

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្ដុះបណ្ដាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP។

## សេចក្ដីណែនាំ

លើកទឹកចិត្តអ្នកចូលរួមឲ្យសួរសំណួរអំពីព័ត៌មានដូចខាងក្រោម។

ចូរពន្យល់ថា ការជួញដូរគឺជាបញ្ហាដែលធ្វើឲ្យមនុស្សមិនស្បាយចិត្តសោះ បំផុតរួមទាំងមានការបំពានសិទ្ធិមនុស្សច្រើនប្រភេទ។ ដើម្បីឲ្យយុវជនមានស្មារតីប្រុងប្រយ័ត្នចំពោះភាពគ្រោះថ្នាក់នៃការជួញដូរដែលអាចកើតមាន ឧបករណ៍នាវិកវៃឆ្លាតនេះរួមបញ្ចូលរឿងរ៉ាវ និងប្រធានបទ ដែលអាចនឹងធ្វើឲ្យអ្នកចូលរួម មិនសប្បាយចិត្ត។

ចូរពន្យល់ថាទាំងនេះគឺជាយុទ្ធសាស្ត្រមួយចំនួនដើម្បីជួយអ្នកសម្របសម្រួលមានការយល់ដឹងអំពីអារម្មណ៍អ្នកដទៃ នៅពេលពិភាក្សាពីបញ្ហានេះ។

## សហការជាមួយឪពុកម្តាយ/អាណាព្យាបាល

ចូរពន្យល់ថា ឧបករណ៍នារីកវៃឆ្លាតនេះផ្តល់ដំបូន្មានថា អ្នកសម្របសម្រួលក្លឹប SNYC គួរជួបប្រជុំជាក្រុមជាមួយឪពុកម្តាយឬអាណាព្យាបាលនិងយុវជន ដើម្បីពិភាក្សាអំពីឧបករណ៍នារីកវៃឆ្លាតនេះនៅក្នុងសិក្ខាសាលាមុនពេលចាប់ផ្តើមឧបករណ៍នារីកឆ្លាតនេះ។ ក្នុងការប្រជុំនេះ អ្នកសម្របសម្រួលក្លឹប SNYC គួរប្រាប់ទៅឪពុកម្តាយ/អាណាព្យាបាលអំពីប្រធានបទ ដែលមាននៅក្នុងឧបករណ៍នារីកវៃឆ្លាតនេះ ហើយសួរថា តើមានប្រធានបទណាដែលឪពុកម្តាយ / អាណាព្យាបាល មិនចង់ឲ្យកូនរបស់ខ្លួនរៀនឬអត់។ ប្រធានបទទាំងអស់នេះនឹងជួយឲ្យយុវជនការពារខ្លួន ប៉ុន្តែ SNYC នឹងមិនបង្រៀន ប្រធានបទនៃមេរៀនមួយទៅយុវជនទេ ប្រសិនបើឪពុកម្តាយ ឬអាណាព្យាបាលបដិសេធ។ SNYC ក៏សុំការអនុញ្ញាតពីឪពុកម្តាយ / អាណាព្យាបាល មុនពេលពិភាក្សាប្រធានបទទាំងនេះដែរ ដោយសុំឲ្យឪពុកម្តាយ/អាណាព្យាបាល ចុះហត្ថលេខាលើលិខិតយល់ព្រម។

## អាយុ ឬបទពិសោធន៍ ដែលសក្តិសម

ចូរពន្យល់ថា ឧបករណ៍នារីកវៃឆ្លាតនេះ ត្រូវបានបង្កើតឡើងសម្រាប់យុវជនអាយុ១២ ទៅ១៧ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ «មេរៀនទី៧៖ ការជួញដូរដើម្បីពលកម្មកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទ»នៅក្នុងឧបករណ៍នារីកឆ្លាតនេះប្រហែលជាមិនសក្តិសមសម្រាប់យុវជនដែលមានវ័យក្មេងជាងនេះឡើយ។ អង្គការទស្សនៈពិភពលោក សហការជាមួយយុវជនដែលមានស្ថានភាពជីវិតច្រើនប្រភេទ ដោយផ្តោតសំខាន់លើយុវជនងាយរងគ្រោះបំផុត។ ក្នុងករណីខ្លះ អាចមានអ្នកចូលរួមជា យុវជននៅក្នុងក្លឹប SNYC ដែលធ្លាប់មានបទពិសោធន៍ច្រើនជាងមនុស្សពេញវ័យ។ ឧទាហរណ៍ អំពីករណីនេះ គឺក្លឹប SNYC មួយ ដែលសហការជាមួយកុមារអាយុ១៣ឆ្នាំ ដែលប្រកបរបររកស៊ីផ្លូវភេទ។ នៅក្នុងករណីនេះ អ្នកសម្របសម្រួលក្លឹប SNYC អាចសម្រេចថា ចាំបាច់ត្រូវនិយាយអំពីមេរៀននេះ ទោះបីជាយុវជននោះនៅក្មេងនៅឡើយក៏ដោយ ព្រោះវាដោះស្រាយបញ្ហាសំខាន់នៅក្នុងជីវិតរបស់ពួកគាត់។ ប៉ុន្តែ ក្លឹប SNYC មួយផ្សេងទៀត ដែលធ្វើការនៅក្នុងសហគមន៍សាសនាបែបប្រពៃណីនិយមមួយអាចសម្រេចចិត្តបង្រៀនមេរៀនទី៧ ទៅឲ្យតែយុវជនដែលមាន អាយុលើ១៦ឆ្នាំប៉ុណ្ណោះ ឬក៏អត់សោះតែម្តង។ អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ត្រូវធ្វើការសម្រេចចិត្តបែបនេះជាមួយនឹងឪពុកម្តាយរបស់យុវជន។

## របៀបនិយាយអំពីបញ្ហាងាយប៉ះពាល់ដល់អារម្មណ៍

ប្រធានបទជាច្រើនក្នុងឧបករណ៍នារីកវៃឆ្លាតនេះ មានលក្ខណៈពិបាកពិភាក្សាណាស់។ អ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់ត្រូវមានសមត្ថភាពនិយាយអំពីប្រធានបទទាំងនេះ ដោយអារម្មណ៍ធូរស្រាល និងមានហេតុផល។ ក្នុងនាមជាអ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់អ្នក ត្រូវសង្កេតអំពីអារម្មណ៍ខ្លួនឯងផ្ទាល់ពាក់ព័ន្ធនឹងបញ្ហា ទាំងនេះ។ ពួកគាត់ចាំបាច់

ត្រូវអាចនិយាយអំពីបញ្ហាផ្លូវភេទ ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ (CSEC) និងការជួញដូរ ដោយពុំមានការភ័យខ្លាច ឬខកចិត្តឡើយ នៅពេលកំពុងរៀន។

ក្លឹប SNYC ក្នុងប្រទេសចិន នឹងធ្វើការជាមួយយុវជនដែលរស់នៅក្នុងសាសារៀនដែលមានកន្លែងស្នាក់នៅ ហើយប្រហែលជាមានចំណេះដឹងតិចតួចណាស់អំពីការរួមភេទ។ SNYC ទាំងនេះ គួរចាប់ដៃគូជាមួយអង្គារ NGO ក្នុងស្រុក មួយទៀតដែលធ្វើការក្នុងផ្នែកពន្យារកំណើត ឬក្នុងផ្នែកបង្ការមេរោគអេសដស៍។ នៅពេលនោះអង្គការNGOដៃគូនេះទៅកាន់SNYCដើម្បីផ្តល់មេរៀនបន្ថែមទៀតដែលពន្យល់អំពីមូលដ្ឋាននៃការរួមភេទ ដល់យុវជនដែលមានអាយុច្រើន (អាយុ១៥ ទៅ១៧ឆ្នាំ) ដើម្បីឲ្យពួកគាត់អាចការពារខ្លួនបានល្អជាងមុននៅពេលអនាគត។

## សកម្មភាព៖ ពិភាក្សាប្រធានបទពិបាកៗ

ចូរពន្យល់ថាសកម្មភាពនេះផ្តោតទៅលើប្រធានបទពិបាកៗមួយចំនួននៅក្នុងឧបករណ៍នារីកវៃឆ្លាត។

អានប្រធានបទនីមួយៗនៅក្នុងចំណុចខាងក្រោមនេះឲ្យឮៗ៖

- យុវជនដែលធ្វើការនៅកន្លែងពេស្យា
- យុវជនដែលរងការបំពានផ្លូវភេទពីឪពុកម្តាយ
- យុវជនដែលរងការវាយដំពីឪពុកម្តាយ
- យុវជនដែលត្រូវបានជួញដូរដោយឪពុកម្តាយ
- យុវជនដែលប្រើគ្រឿងញៀនខុសច្បាប់
- ឪពុកម្តាយដែលផឹកគ្រឿងស្រវឹងច្រើនពេក
- ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី
- យុវជន ដែល ពេលខ្លះមិនយល់ស្របជាមួយនឹងមនុស្សពេញវ័យដើម្បីសុត្ថិភាព
- យុវជនដែលរំលោភច្បាប់ នៅពេលពួកគាត់ធ្វើចំណាកស្រុកខុសច្បាប់

ពេលអ្នកអានប្រធានបទនីមួយៗ ប្រាប់អ្នកចូលរួមឲ្យរៀបចំតម្រង់ជួរទៅតាមលក្ខណៈវិនិច្ឆ័យខាងក្រោម។ ឧទាហរណ៍ ប្រសិនបើអ្នកចូលរួមណាម្នាក់មានអារម្មណ៍រីករាយពិភាក្សាប្រធានបទយុវជនដែលធ្វើការនៅកន្លែងពេស្យានោះ អ្នកចូលរួមរូបនោះនឹងឈរនៅចុងបំផុតម្ខាងនៃជួរ ខណៈដែលអ្នកណាម្នាក់ដែលមានអារម្មណ៍មិនរីក រាយពិភាក្សាប្រធានបទនេះនឹងឈរនៅចុងបំផុតម្ខាងទៀតនៃជួរដដែលនេះ។ ចំពោះប្រធានបទនីមួយៗនៅលើប័ណ្ណព័ត៌មាន ពួកគាត់នឹងរៀបចំតម្រង់ជួរឡើងវិញពីរដង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងក្រោមនិងផ្អែកលើអារម្មណ៍របស់ពួកគាត់។

ពិបាកពិភាក្សា ⟷ ស្រួលពិភាក្សា

មានការខ្វែងគំនិតគ្នាក្នុងសហគមន៍ ⟷ មិនខ្វែងគំនិតគ្នាក្នុងសហគមន៍

បន្ទាប់មកប្រាប់ឲ្យក្រុមមករួមគ្នា ហើយពិភាក្សាសំណួរខាងក្រោមនេះ ៖

បន្ទាប់មកប្រាប់ឲ្យក្រុមមករួមគ្នា ហើយពិភាក្សាសំណួរខាងក្រោមនេះ ៖

- តើលំដាប់ជួរ មានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ឬទេ?
- តើមានប្រធានបទណាដែលពិបាកសម្រាប់ឲ្យយុវជនពិភាក្សា ឬទេ? តើមានការខ្វែងគំនិតគ្នាខ្លាំងទេនៅក្នុង សហគមន៍ដែរ?
- តើអ្នកនឹងធ្វើដូចម្ដេច ក្នុងស្ថានភាពបែបនេះ?
- តើអ្នកនឹងយកចិត្តទុកដាក់ទៅលើតម្រូវការរបស់កុមារ ឬទស្សនៈរបស់សហគមន៍?
- តើអាចជួយកុមារ ដោយមិនធ្វើឲ្យសហគមន៍អន់ចិត្ត ឬទេ?
- ប្រសិនបើអាច តើត្រូវជួយដោយរបៀបណា?

### សង្ខេបមេរៀន

- ឧបករណ៍នារីកវីឆ្លាតនេះ ពិភាក្សាអំពីប្រធានបទទាក់ទងនឹងបញ្ហាផ្លូវភេទ ឬបញ្ហាដែលរំខានចិត្ត។
- ក្លឹប SNYC សុំការអនុញ្ញាតពីឪពុកម្ដាយ/អាណាព្យាបាល មុនពេលពិភាក្សាប្រធានបទទាំងនេះ ដោយ សុំឲ្យពួកគាត់ចុះហត្ថលេខាលើលិខិតយល់ព្រម ។
- អ្នកសម្របសម្រួលក្លឹប SNYC អាចសម្រេចចិត្តបង្រៀនតែយុវជនដែលមានអាយុច្រើន នូវមេរៀនទី៧៖ «ការជួញដូរដើម្បីពលកម្មកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទ» នៅក្នុង SNYC ។
- អ្នកសម្របសម្រួលក្លឹប SNYC អាចសម្រេចចិត្តបែងចែកអ្នកចូលរួមជាក្រុមដាច់ដោយឡែក ក្មេងប្រុស និង ក្មេងស្រី នៅពេលខ្លួនបង្រៀនមេរៀនទី៧។
- អ្នកសម្របសម្រួល គួរមានសមត្ថភាពពិភាក្សាប្រធានបទពិបាក ឬទាក់ទងនឹងផ្លូវភេទនៅក្នុងសម្ដីដែល មានអារម្មណ៍ធូរស្រាល និង មិនរំជួលចិត្ត ។

# មេរៀនទី៩ ៖ ការការពារកុមារនៅក្នុងក្លឹប SNYC

## ទស្សនៈ

មេរៀននេះ ប្រើប្រាស់ព័ត៌មានផ្អែកទៅលើអនុសាសន៍នៃគោលការណ៍ណែនាំដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះកុមារដែលមានអារម្មណ៍ទុក្ខព្រួយរបស់អង្គការទស្សនៈពិភពលោក។ អ្នកចូលរួមនឹងយល់ដឹងអំពីរបបឆ្លើយតបចំពោះកុមារដែលមានអារម្មណ៍ទុក្ខព្រួយ និងត្រូវបានណែនាំឲ្យស្គាល់លក្ខណៈសំខាន់ៗនៃគោលនយោបាយការពារកុមាររបស់អង្គការទស្សនៈពិភពលោក ដែលត្រូវបានដាក់បញ្ចូលក្នុងសៀវភៅណែនាំនេះ។

ទោះជាយ៉ាងណាក៏ដោយ មេរៀននេះ មិនត្រូវបានបង្កើតឡើងដើម្បីជំនួសឲ្យគោលនយោបាយការពារកុមារ ដែលអ្នកសម្របសម្រួលក្លឹប SNYC ទាំងអស់គួរត្រូវចុះហត្ថលេខា មុនពេលចាប់ផ្តើមស្ម័គ្រធ្វើការនៅក្លឹប SNYC នោះទេ។

## រយៈពេល

៦០ នាទី

## សម្ភារ

- សៀវភៅណែនាំសម្រាប់អ្នកចូលរួមនីមួយៗ

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ ២-៣ រូប មកពីក្លឹប SNYC នីមួយៗ

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំប្រទេស ដែលបានចូលរួមការបណ្តុះបណ្តាលក្លឹប SNYC នៅក្នុងកម្មវិធី ETIP ។

## សេចក្តីណែនាំ

### ការឆ្លើយតបចំពោះយុវជនដែលមានអារម្មណ៍ទុក្ខព្រួយ

ចូរពន្យល់ថា ប្រធានបទដែលងាយប៉ះពាល់ដល់អារម្មណ៍ដែលត្រូវបាន

ពិភាក្សាក្នុងឧបករណ៍នារីកវៃឆ្លាតនេះ អាចធ្វើឲ្យអ្នកចូលរួមជាយុវជនមានអារម្មណ៍ខកចិត្ត។ ប្រសិនបើយុវជនម្នាក់ចាប់ផ្តើមយំក្នុងអំឡុងរៀននោះ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរនិយាយចំអន់យុវជននោះ ឬប្រាប់ឲ្យយុវជននោះឈប់យំនោះទេ។ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរសួរអ្នកចូលរួមនោះថាហេតុអ្វីបានជាយំ ប៉ុន្តែគួរអនុញ្ញាតឲ្យយុវជននោយំ។ ប្រសិនបើឃើញថាសមស្របអ្នកសម្របសម្រួលអាចលួងលោមយុវជននោះ ដោយយកដៃដាក់លើស្មា ឬអនុញ្ញាតឲ្យយុវជនដទៃទៀតធ្វើជំនួសវិញ។ អ្នកសម្របសម្រួលក្លឹប SNYC គួរតាមដានយុវជននោះបន្តទៀត ក្រោយពីបញ្ចប់មេរៀន។

ប្រសិនបើអ្នកចូលរួមជាយុវជនណាម្នាក់ ចង់ចាកចេញនៅពេលកំពុងរៀន ពីព្រោះគាត់មានអារម្មណ៍អន់ចិត្តនោះ សូមអនុញ្ញតឲ្យអ្នកចូលរួមនោះចាកចេញទៅហើយតាមដានគាត់នៅពេលក្រោយ។

ចូរពន្យល់ថា ក្នុងពេលដំណើរការការងារ ក្នុងនាមអ្នកជាអ្នកសម្របសម្រួលក្លឹប SNYC អាចនឹងមានអ្នកចូលរួមម្នាក់ជាយុវជន ឡើងមកបង្ហាញថា គាត់ធ្លាប់ជាជនរងគ្រោះនៃការរំលោភបំពានលើកុមារ។ ប្រសិនបើមានរឿងបែបនេះកើតឡើង អ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់ត្រូវចាត់វិធានការ។

ការរំលោភបំពានលើកុមារ សំដៅលើកាលដែលកុមារម្នាក់ត្រូវបានរំលោភបំពានលើរាង្គកាយ ឬ ផ្លូវភេទពីសំណាក់មនុស្សពេញវ័យ។ អ្នកសម្របសម្រួលក្លឹប SNYC អាចរកឃើញថា៖

- យុវជនម្នាក់មានអារម្មណ៍អន់ចិត្តចំពោះប្រធានបទមួយនៅក្នុងមេរៀន ហើយក្រោយមកប្រាប់ថា មនុស្សពេញវ័យមួយរូបកំពុងរំលោភបំពានខ្លួន។
- យុវជនម្នាក់ទទួលស្គាល់ថា មនុស្សពេញវ័យមួយរូបកំពុងរំលោភបំពានខ្លួន (ការទទួលស្គាល់នេះអាចកើត ឡើង នៅពេលដែលយុវជនម្នាក់ចាប់ផ្តើមជឿទុកចិត្តលើអ្នកសម្របសម្រួល)។
- អ្នកសម្របសម្រួល អាចធ្វើជាសាក្សីថា យុវជនម្នាក់ត្រូវបានរំលោភបំពានដោយមនុស្សពេញវ័យ។

ពន្យល់ថា នៅពេលណាយុវជនម្នាក់និយាយថាខ្លួនត្រូវបានរំលោភបំពាននោះ អ្នកសម្របសម្រួប SNYC គួរ តែយកចិត្តទុកដាក់។ កុំទាត់ចោលរឿងរ៉ាវរបស់យុវជន ឬធ្វើហាក់ដូចជាអ្នកគិតថាយុវជននោះកំពុងតែកុហក។ យុវជនកម្រនិយាយកុហកអំពីការរំលោភបំពានណាស់។ ទោះជាយ៉ាងណាក៏ដោយ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរចាត់វិធានការដោយផ្ទាល់ខ្លួន ឬដោយឆេវឆាវនោះទេ។ នៅពេលណាដែលយុវជនម្នាក់រាយការណ៍អំពីការ រំលោភបំពាន អ្នកសម្របសម្រួលក្លឹប SNYC គួរអនុវត្តតាមផែនការឆ្លើយតបរបស់ការិយាល័យប្រចាំប្រទេសរបស់អង្គការទស្សនៈពិភពលោក ដែលមាននៅក្នុងឧបសម្ព័ន្ធខ ក្នុងសៀវភៅណែនាំនេះ។

### *គោលការណ៍ណែនាំការពារកុមារ*

ផ្នែកនេះផ្តោតទៅលើគោលការណ៍ណែនាំដើម្បីអនុវត្តតាមបទដ្ឋានការពារកុមារ

របស់អង្គការទស្សនៈពិភពលោក ខែកញ្ញា ឆ្នាំ២០១២ ។

ចូរពន្យល់ថា អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ចាំបាច់ត្រូវចុះហត្ថលេខាលើគោលនយោបាយការពារកុមាររបស់អង្គការទស្សនៈពិភពលោកក្នុងប្រទេសរបស់ពួកគាត់។ អ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់ត្រូវអានគោលនយោបាយការពារកុមារដែលជាឧបសម្ព័ន្ធកក្នុងឧបករណ៍នាវិកវៃឆ្លាតនេះ ដោយម៉ត់ចត់ ហើយត្រូវប្រាកដថា ពួកគាត់យល់នូវអ្វីដែលអ្នកសម្របសម្រួលក្លឹប SNYC បានរំពឹងទុក ។

មេរៀននេះ ពន្យល់អំពីបញ្ហាសំខាន់ៗមួយចំនួននៅក្នុងគោលនយោបាយការពារកុមារ និងពន្យល់អំពីខ្លឹមសារនៃបញ្ហាទាំងនោះ ទាក់ទងនឹងក្លឹប SNYC។

ចូរពន្យល់ថា អង្គការទស្សនៈពិភពលោកឲ្យនិយមន័យកុមារថា ជាមនុស្សម្នាក់ដែលមានអាយុក្រោម១៨ឆ្នាំ ហេតុនេះ អ្នកសម្របសម្រួលក្លឹប SNYC គឺជា «កុមារ»។

## *ធ្វើឲ្យមានជាអប្បបរមានូវការប៉ះពាល់រាងកាយជាមួយយុវជន*

ចូរពន្យល់ថា ការប៉ះពាល់រាងកាយមានន័យថា ពេលណាក៏ដោយដែលអ្នកសម្របសម្រួលក្លឹប SNYC ប៉ះពាល់យុវជន។ អង្គការទស្សនៈពិភពលោកនិយាយថា អ្នកសម្របសម្រួលក្លឹប SNYC «គួរធានាថារាល់ការប៉ះពាល់លើរាងកាយជាមួយយុវជន គឺសមស្របទៅតាមតំបន់»។ មិនមែនការប៉ះពាល់រាងកាយទាំងអស់សុទ្ធតែអាក្រក់នោះទេ។ ឧទាហរណ៍ អ្នកសម្របសម្រួលក្លឹប SNYC ដែលដាក់ដៃលើស្មារបស់យុវជនម្នាក់ដើម្បីលួងលោមយុវជនរូបនោះ គឺជាទម្រង់នៃការប៉ះពាល់រាងកាយដែលអាចទទួលយកបាន។ ប៉ុន្តែ ដោយសារទាំងការ រំលោភបំពានផ្លូវភេទនិងរាងកាយមាននូវការប៉ះពាល់រាងកាយនោះ អ្នកសម្របសម្រួលក្លឹប SNYC ចាំបាច់ត្រូវប្រុងប្រយ័ត្ន នៅពេលណាដែលពួកគាត់ប៉ះពាល់យុវជន។ អ្នកចូលរួមជាយុវជននៅក្នុង SNYC មានអាយុ១២ទៅ១៧ឆ្នាំ។ យុវជនទាំងនេះ មានអាយុច្រើនគ្រប់គ្រាន់ ដែលមិនសក្តិសមសម្រាប់អ្នកសម្របសម្រួលឱបឬថើបនោះទេ។ចូរពន្យល់ថា ដើម្បីទប់ស្កាត់ការយល់ច្រឡំ ឬការចោទប្រកាន់នៃការរំលោភបំពានផ្សេងៗ អង្គការទស្សនៈពិភពលោកបានណែនាំឲ្យអ្នកសម្របសម្រួលក្លឹប SNYC ឲ្យប៉ះពាល់រាងកាយអ្នកចូលរួមជាយុវជនក្នុងកម្រិតតិចបំផុត។

អ្នកសម្របសម្រួលក្លឹប SNYC គួរប្រើប្រាស់ «វិធីសាស្ត្រវិជ្ជមានបែបអហិង្សា ដើម្បីគ្រប់គ្រងអាកប្បកិរិយារបស់យុវជន»។ មិនគួរវាយ ឬច្រានយុវជន នៅក្នុងក្លឹប SNYC ឡើយ ។

អ្នកសម្របសម្រួលក្លឹប SNYC មិនគួរប្រើប្រាស់ «ភាសាដែលធ្វើឲ្យមានការអៀនខ្មាស់ ឬប្រមាថ ឬដែលមានលក្ខណៈមើលស្រាល និង មិនផ្តល់តម្លៃ» ។

ប្រសិនបើយុវជនណាម្នាក់បញ្ចេញអាកប្បកិរិយាមិនសមរម្យទាក់ទងផ្លូវភេទ ដាក់អ្នកសម្របសម្រួលក្លឹប SNYC ណាម្នាក់ អ្នកសម្របសម្រួលក្លឹប SNYC នោះ មិនគួរឆ្លើយតបវិញក្នុង

[7] នេះអាចរកបានសម្រាប់បុគ្គលិកអង្គការទស្សនៈពិភពលោកនៅ wvcentral នៅ https://www.wvcentral.org/community/cwbr/Documents_03/CPA Project Model/Life Skills and Resilience Resources/Preventing and Responding to Distress in Child Participation 24 Jan.doc.

លក្ខណៈទាក់ទងផ្លូវភេទនោះទេ។ អ្នកសម្របសម្រួលនោះ គួរជៀសវាងកុំស្ថិតនៅក្នុងជំហរសម្របសម្រួល ឬងាយរងគ្រោះជាមួយនឹងយុវជន»។ អ្នកសម្របសម្រួលនោះ គួរទូរស័ព្ទទៅអ្នកគ្រប់គ្រងរបស់ខ្លួននៅថ្ងៃជាមួយគ្នានេះ ដើម្បីរៀបរាប់ប្រាប់អំពី ឧប្បទ្ទវហេតុនេះ ហើយពិភាក្សាអំពីរបៀបឆ្លើយតប។

អ្នកសម្របសម្រួលក្លឹប SNYC មិនអាចមានទំនាក់ទំនងស្នេហា ឬផ្លូវភេទជាមួយយុវជនឡើយ។ ដើម្បីទប់ស្កាត់កុំឲ្យអាកប្បកិរិយាមិនសមរម្យកើតឡើង ពួកគាត់មិនគួរទៅទទួលទានអាហារខាងក្រៅ ឬទៅចូលរួមកម្មវិធីសង្គមផ្សេងៗ ជាមួយយុវជនឡើយ។ កម្មវិធីផ្លូវការដែលឧបត្ថម្ភដោយក្លឹប SNYC ដោយមានការចូលរួមពីអ្នកចូលរួមជាយុវជនទាំងអស់ និងមនុស្សពេញវ័យផ្សេងទៀត គឺជាករណីលើកលែងចំពោះច្បាប់នេះ។

### *កុំនៅតែម្នាក់ឯងជាមួយយុវជន*

អ្នកសម្របសម្រួលក្លឹប SNYC «តាមដែលអាចទៅបាន និងអនុវត្តបាន គួរអនុវត្តតាមច្បាប់ «មនុស្សពេញវ័យពីរនាក់» ពេលប្រតិបត្តិការងារ ដែលក្នុងករណីដូចនេះ មនុស្សពេញវ័យពីរ ឬច្រើននាក់ត្រួតពិនិត្យសកម្មភាពទាំងអស់ដែលពាក់ព័ន្ធយុវជន ហើយអាចត្រូវបានមើលឃើញ និងមានវត្តមានគ្រប់ពេល»។ ក្នុងឧបករណ៍នារីកឆ្លាតនេះអង្គការទស្សនៈពិភពលោកលើកទឹកចិត្តឲ្យអ្នកសម្របសម្រួលនៅក្នុងក្លឹបសិន បន្ទាប់ពី SNYC បញ្ចប់ ដើម្បីរង់ចាំក្រែងមានអ្នកចូលរួមណាម្នាក់ ចង់និយាយជាមួយ។ ទោះជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវមានមនុស្សពេញវ័យមួយរូបទៀតនៅក្នុងបន្ទប់ ឬមួយពួកគាត់គួរអង្គុយនៅក្រៅទ្វារនៅទីវាលដែលអ្នកដើរឆ្លងកាត់ អាចមើលឃើញបាន។ ការធ្វើដូច្នេះ គឺដើម្បីការពារយុវជន ប៉ុន្តែវាក៏ការពារអ្នកសម្របសម្រួលមិនឲ្យរងការចោទប្រកាន់ខុសឆ្គង ថាមានអាកប្បកិរិយាមិនសមរម្យផងដែរ។

អ្នកសម្របសម្រួលក្លឹប SNYC «មិនគួរចំណាយពេលវេលាហួសហេតុ ឬមិនចាំបាច់តែម្នាក់ឯងជាមួយយុវជននៅដាច់ឆ្ងាយពីអ្នកដទៃ ឬនៅក្នុងបន្ទប់បិទជិត ឬក្នុងកន្លែងស្ងាត់ដែលនៅដាច់ពីគេនោះឡើយ»។

អ្នកសម្របសម្រួលក្លឹប SNYC មិនគួរនៅតែម្នាក់ឯងជាមួយយុវជននៅក្នុងរថយន្តទេ ទោះជាសម្រាប់ការងារអង្គការទស្សនៈពិភពលោកក៏ដោយ លុះត្រាតែវាពិតជាចាំបាច់ខ្លាំងជាទីបំផុត ហើយមានការអនុញ្ញាតពីឪពុកម្តាយ/អាណាព្យាបាលរបស់យុវជន និងមានការអនុញ្ញាតពីអ្នកគ្រប់គ្រងក្លឹប SNYC។

### *ចូរកុំលើកលែងចំពោះអាកប្បកិរិយាខុសច្បាប់*

អ្នកសម្របសម្រួលក្លឹប SNYC មិនគួរ «លើកលែង ឬចូលរួមក្នុងអាកប្បកិរិយាជាមួយយុវជន ដែលខុសច្បាប់អសុវត្ថិភាព និងបង្កការរំលោភបំពាននោះទេ រួមមានការអនុវត្តតាមប្រពៃណីដែលអាចមានគ្រោះថ្នាក់ ការរំលោភបំពានតាមបែបព្រលឹង ឬតាមពិធីសាសនា»។ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរលើកលែងទម្រង់ណាមួយនៃការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមយុវជននោះទេ។ អ្នកសម្របសម្រួលក្លឹប SNYC មិនគួរសេពគ្រឿងស្រវឹងជាមួយ

យុវជននោះទេ។

អ្នកសម្របសម្រួលក្លឹប SNYC មិនគួរជួលយុវជនឲ្យធ្វើការងារក្នុងទម្រង់ណាមួយនៃពលកម្មកុមារនោះទេ ជាពិសេស ពួកគាត់មិនគួរជួលយុវជនឲ្យធ្វើការងារជា «អ្នកជួយកិច្ចការនៅផ្ទះ»។

*ការពិភាក្សា*

- សួរអ្នកចូលរួមថាតើពួកគាត់មានសំណួរអំពីរបៀបឆ្លើយតបចំពោះយុវជនដែលមានអារម្មណ៍ទុក្ខព្រួយ ឬទេ។
- សួរអ្នកចូលរួមថាតើពួកគាត់មានសំណួរណាអំពីការការពារកុមារនៅក្នុងអង្គការទស្សនៈពិភពលោកឬទេ។

**សង្ខេបមេរៀន**

- ប្រសិនបើយុវជនណាម្នាក់មានអារម្មណ៍អន់ចិត្តក្នុងពេលកំពុងរៀន អ្នកសម្របសម្រួលគួរអនុញ្ញាតឲ្យយុវជននោះមានអារម្មណ៍អន់ចិត្តចុះ ដោយមិនចាំបាច់យកចិត្តទុកដាក់ទៅលើគាត់នោះទេ ហើយបន្ទាប់មកតាមដានគាត់ក្រោយបញ្ចប់ម៉ោងរៀន។
- ប្រសិនបើយុវជនណាម្នាក់មានអារម្មណ៍អន់ចិត្ត ហើយចង់ចាកចេញពីម៉ោង រៀន គាត់គួរត្រូវបានអនុញ្ញាតឲ្យចាកចេញ។
- ប្រសិនបើយុវជនណាម្នាក់រាយការណ៍ថា ខ្លួនកំពុងទទួលរងនូវការរំលោភ បំពានរាង្គកាយឬផ្លូវភេទនោះអ្នកសម្របសម្រួលក្លឹបSNYCគួរទូរស័ព្ទទៅអ្នកគ្រប់គ្រងក្លឹប SNYC នៅថ្ងៃនោះ ហើយគួរអនុវត្តតាមផែនការឆ្លើយតបនៅក្នុងឧបសម្ព័ន្ធខ ក្នុងឧបករណ៍នាវិកវៃឆ្លាត។
- អ្នកសម្របសម្រួលក្លឹប SNYC គួរចុះហត្ថលេខា និងប្រកាន់ខ្ជាប់គោលនយោបាយការពារកុមាររបស់អង្គការទស្សនៈពិភពលោក ហើយគួរៈ
  - ➢ មានប៉ះពាល់រាង្គកាយយុវជនតិចតួចបំផុត
  - ➢ កុំនៅតែម្នាក់ឯងជាមួយយុវជន
  - ➢ កុំលើកលែងអាកប្បកិរិយាខុសច្បាប់
  - ➢ កុំជួលយុវជនឲ្យធ្វើការងារ

[8] នេះអាចរកបានសម្រាប់បុគ្គលិកអង្គការទស្សនៈពិភពលោកនៅ wvcentral នៅ https://www.wvcentral.org/visionfund/Internal Resources/Guidelines for Implementation of Child Protection Standards.doc.